# វេយ្យាករណ៍ខ្មែរ

## មានភ្ជាប់ជាមួយវចនានុក្រមខ្មែរកំណែទី២

## លំនាំដើម

មុនដំបូងខ្ញុំគិតថាសរសេរអំពី «**វិធីសរសេរតែងនិពន្ធ**» ដោយសង្ខេបប៉ុណ្ណោះ ប៉ុន្តែពេលក្រោយមក អស់លោកជាអ្នកផ្តួចផ្តើមគំនិត លោកមានសំណូមពរ សូមឲ្យបន្ថែមសេចក្តីណែនាំមួយចំនួនទាក់ទងទៅនឹងវេយ្យាករណ៍ផង នោះទើបខ្ញុំក៏ពិចារណាទៅឃើញថា ប្រសិនបើមិនចេះ ឬចេះវេយ្យាករណ៍ស្ទើរៗ សើៗ ញ្រូលៗ នោះការសរសេរតែងនិពន្ធ ប្រាកដជាមានចំណុចខ្វះខាតច្រើនមិនខាន ។ ដូច្នេះខ្ញុំក៏យល់ស្រប ហើយសម្រេចបញ្ចូលចំណុចសំខាន់ៗមួយចំនួននៃចំណេះខាងវេយ្យាករណ៍ខ្មែរ នៅភាគខាងដើមនៃសៀវភៅនេះ ។ ធ្វើដូច្នេះ ដោយចង់រំលឹកអ្នកចង់ចេះសរសេរតែងនិពន្ធទាំងឡាយ មិនឲ្យមើលស្រាលចំណេះខាងវេយ្យាករណ៍ ប្រសិនបើគេចង់សរសេរឲ្យបានល្អ ។ លុះកាលណាអ្នកអាន ឬអ្នកសិក្សាចាប់បាននូវផ្នែកសំខាន់ៗនៃវេយ្យាករណ៍ ធ្វើឲ្យគេទទួលបាននូវពន្លឺ និងគោលការណ៍នៃការតែងនិពន្ធហើយនោះ ទើបខ្ញុំជួយឲ្យអស់លោកទៅជួបនឹងចំណេះដឹងជាសារវន្តទាក់ទងដល់ ការសរសេរតែងនិពន្ធ ។ ដើម្បីកុំឲ្យសៀវភៅនេះក្រាស់ពេក ហើយដោយយល់ឃើញថា វេយ្យាករណ៍ខ្មែរនេះ មានរៀមច្បងមួយចំនួនបានសរសេរលម្អិតហើយនោះ ដូច្នេះខ្ញុំគ្រាន់តែសូមជួយរំលឹកតែត្រង់ផ្នែកសំខាន់ខ្លះ ដែលអ្នកសរសេរតែងនិពន្ធត្រូវដឹងដោយខានពុំបាន ។ ឯនៅភាគទី២នេះទៀតសោត ក៏ខ្ញុំពុំបានធ្វើឲ្យមានការលម្អិតពិស្តារជ្រៅជ្រះប៉ុន្មានទេ ។ សំខាន់គឺគ្រាន់តែលើកមកបង្ហាញត្រួសៗនូវចំណុចចាំបាច់ខ្លះ ដើម្បីផ្តល់ជូនអ្នកអាន អ្នកសិក្សានូវសញ្ញាណស្តីពីរបៀបសរសេរតែងនិពន្ធ ។ របៀប និងវិធីសរសេរមានច្រើនណាស់... ។ អស់លោកត្រូវខំព្យាយាមអានសៀវភៅគ្រប់ប្រភេទឲ្យបានច្រើនទាំងបុរាណ ទាំងទំនើប ទាំងកំណាព្យកម្រងកែវ និងអត្ថបទសម្រាយធម្មតា... ។ អរគុណដែលបានចាប់អារម្មណ៍ចំពោះមុខវិជ្ជានេះ ។ សូមជូនពរការខិតខំសិក្សាទទួលបានលទ្ធផលល្អ ។

*មៀច ប៉ុណ្ណ*

# ផ្នែកទី១

## អំពីអក្សរ ឬអក្ខរៈ

អក្សរ តាមពាក្យសំស្រ្កឹត មានន័យថា ទន់ភ្លន់ អាចបត់បែនបាន អាចយកទៅច្នៃបាន តាមការផ្សំជាមួយស្រៈ តាមការប្រកបជាមួយនឹងព្យញ្ជនៈមួយទៀត ឬតាមការផ្សំជាមួយជើងអក្សរណាមួយ ។

អក្សរ ឬអក្ខរៈ អាចហៅបានម្យ៉ាងទៀតថា «**វណ្ណៈ**» មានចែកជាបីក្រុមគឺ ៖

1. **ព្យញ្ជនៈ** មាន ៣៣តួ ។
2. **ស្រៈពេញតួ** ១២តួ ។
3. **ស្រៈនិស្ស័យ** ពីមុនមាន ២១ តែត្រូវបន្ថែម ៧ ទៀតបានទៅជា ២៨តួ បើគិតទាំងសំឡេង ។ តែបើគិតតែរូបមាន ២៧តួ ព្រោះស្រៈ (អ) មាននៅគ្រប់ព្យញ្ជនៈទាំងឃោសៈទាំងអឃោសៈ ។

### ១-ព្យញ្ជនៈ

ព្យញ្ជនៈទាំង ៣៣តួ ត្រូវរាប់តាមលំដាប់ពីដើមដល់ចប់ ៖

**កខគឃង ចឆជឈញ ដឋឌឍណ តថទធន បផពភម យរលវ សហឡអ**

### ២-ជើងព្យញ្ជនៈ

ព្យញ្ជនៈ ប្រៀបបាននឹងមនុស្សដែរ គឺមានសក់ (◌៎) មានតួខ្លួន (ក) មានជើង (◌្ក) ។ រូបនៃជើងព្យញ្ជនៈមានទ្រង់ទ្រាយដូចគ្នានឹងតួអង្គព្យញ្ជនៈដែរ ប៉ុន្តែគ្រាន់តែតូចជាងតួ និងពុំមាន «**សក់**» ទេ ។ ខាងក្រោមនេះ គឺជើងព្យញ្ជនៈ (Consonnes souscrites) ។

◌្ក ◌្ខ ◌្គ ◌្ឃ ◌្ង, ◌្ច ◌្ឆ ◌្ជ ◌្ឈ ◌្ញ, ◌្ដ ◌្ឋ ◌្ឌ ◌្ឍ ◌្ណ, ◌្ត ◌្ថ ◌្ទ ◌្ធ ◌្ន, ◌្ប ◌្ផ ◌្ព ◌្ភ ◌្ម, ◌្យ ◌្រ ◌្ល ◌្វ ◌្ស ◌្ហ ◌្ឡ ◌្អ

របៀបសរសេរ ជើងព្យញ្ជនៈ ភ្ជាប់ជាមួយតួព្យញ្ជនៈ ដូចខាងក្រោម ៖

**ក្ខខ្គគ្ឃឃ្ង ច្ឆឆ្ជជ្ឈឈ្ញ ដ្ឋឋ្ឌឌ្ឍឍ្ណ ត្ថថ្ទទ្ធធ្ន ប្ផផ្ពព្ភភ្ម យ្ររ្លល្វ ស្ហហ្ឡឡ្អ**

## ៣-ស្រៈពេញតួ

អ្នកប្រាជ្ញជំនាន់មុនចែងថា ស្រៈពេញតួមាន ១៥តួ ដោយរាប់យក **អ អា** មកបញ្ចូលផង ។ ប៉ុន្តែ អ្នកប្រាជ្ញបច្ចុប្បន្នលោកដកយក «**អ**» និង «**អា**» នេះចេញពីប្រព័ន្ធស្រៈពេញតួ ព្រោះលោក យល់ថា «**អ**» គឺជាព្យញ្ជនៈដែលត្រូវរាប់បញ្ចូលទៅក្នុងក្រុមព្យញ្ជនៈ ទាំង៣៣តួនោះវិញ ។ ឯ «**អា**» គឺតួព្យញ្ជនៈបំបែក យកតួ «**អ**» មកផ្សំជាមួយស្រៈ «◌ា» ដូច្នេះស្រៈពេញតួបច្ចុប្បន្ននេះ មានតែ ១៣តួទេ គឺ ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ ។ ចំពោះអស់លោកអ្នកប្រាជ្ញខ្លះទៀត យល់ថា ក្នុងចំណោមស្រៈពេញតួទាំង១៣នេះ ស្រៈ **ឩ** គេមិនសូវប្រើទេ ដូច្នេះ គួររាប់យកត្រឹម តែ ១២តួវិញ ព្រោះសព្វថ្ងៃគេប្រើស្រៈពេញតួ **ឩ** នេះតែពាក្យ «**ព្រះឩរូ**» មួយម៉ាត់គត់ ដែលមាន នៅក្នុងពាក្យ «**រាជស័ព្ទ**» មានន័យថា «**ភ្លៅស្តេច**» ។

## ៤-ស្រៈនិស្ស័យ

គឺ តួអក្សរ ដែលជាទីពឹងពាក់អាស្រ័យនៃព្យញ្ជនៈ ។ បើសរសេរតែរូបវាដាច់តែឯងនោះ នឹងពុំ មានន័យប្រាកដប្រជាថាយ៉ាងណាៗនោះឡើយ ។ ដូចជាស្រៈ ◌ា ស្រៈ ◌ៅ មានតែរូប និង សំឡេងផ្សំ តែពុំមានសារៈអ្វីទេ ។ ស្រៈនិស្ស័យមាន ២១តួ តាមការកំណត់របស់ក្បួនពីមុន នោះគឺ ◌្ ◌ា ◌ិ ◌ី ◌ឹ ◌ឺ ◌ុ ◌ូ ◌ួ ◌ើ ◌ឿ ◌ៀ ◌េ ◌ែ ◌ៃ ◌ោ ◌ៅ ◌ុំ ◌ំ ◌ាំ ◌ះ ។ ប៉ុន្តែអស់លោកអ្នក អក្សរសាស្ត្រក្រោយមកសន្មតថា មានតែ២០តួវិញ ព្រោះថា ស្រៈ(អ) មានតែសំឡេងតែគ្មាន រូប មិនគួរនឹងរាប់បញ្ចូលទេ ។ ស្រៈ(អ) នេះមានបង្កប់នៅគ្រប់ព្យញ្ជនៈទាំងអស់ ទោះជាឃោ សៈក្តី អឃោសៈក្តី ប៉ុន្តែប្រសិនបើគេយកទៅផ្សំជាមួយនឹងព្យញ្ជនៈសំឡេងឃោសៈ គេអាន តាមសំឡេងព្យញ្ជនៈ ឃោសៈ គឺសំឡេង(អ៊) ឧទាហរណ៍ **ងា ងិ ងី ញោ ញៅ ទុំ ទាំ ទះ....** ។ បើ ផ្សំជាមួយនឹងព្យញ្ជនៈអឃោសៈ វាមានសំឡេង (អ) ដូចជា **កា កី កោ ចូ ចើ ចេ ចែ ចៃ ចោ...** ។ ចំពោះស្រៈ ◌ួ ◌ឿ និង ◌ៀ ទោះគេយកទៅផ្សំនឹងព្យញ្ជនៈ ឃោសៈក្តី អឃោសៈក្តី វានៅតែមាន សូរសំឡេង «**អួ**» (អឿ-អៀ) ដូចគ្នា នេះវាជាករណីលើកលែងសម្រាប់ស្រៈនិស្ស័យរបស់ខ្មែរ យើង ។ រីឯស្រៈ៤ទៀតដូចជា ស្រៈ ◌ុះ ◌ិះ ◌េះ ◌ោះ វិញនោះ កាលពីមុនលោកមិនយកមក រាប់បញ្ចូលក្នុងស្រៈនិស្ស័យទេ ។ ប៉ុន្តែនៅពេលក្រោយមក ដោយបានពិនិត្យឃើញថា មាន ពាក្យជាច្រើន ដែលត្រូវការប្រើស្រៈទាំងនេះ នៅក្នុងពាក្យខ្មែរជាចាំបាច់នោះ ទើបលោកអ្នក ប្រាជ្ញជាន់ក្រោយ ក៏បានសម្រេចបញ្ចូលបន្ថែមស្រៈទាំង៤នេះ ហើយស្រៈនិស្ស័យក៏បានកើន

ដល់ (២១-១)+៤ = ២៤ ហើយបើបន្ថែមស្រៈ ឹះ ,ស្រៈ ើះ, ស្រៈ េះ ពីលើស្រៈនិស្ស័យដែលធ្លាប់ឃើញមាននៅក្នុងវចនានុក្រមសម្ដេច **ជួន ណាត** ក្ដី ក្នុងអត្ថបទនានាក្ដីទៀតនោះ ស្រៈនិស្ស័យអាចកើនឡើងដល់ ២៦ ឬ ២៧ [1] ។

## ៥-ការប្រើប្រាស់ជើងអក្សរ

ដោយហេតុថា មានករណីដោយឡែកខ្លះ ដែលពាក់ព័ន្ធទៅនឹងជើងអក្សរព្យញ្ជនៈខ្មែរយើងនោះ ខ្ញុំសូមអនុញ្ញាតជម្រាបថា ៖

ក/ ជើង «**ត្ត**» និងជើង «**ដ្ត**» មានរូបរាងដូចគ្នាអាចច្រឡំ ព្រោះការប្រើប្រាស់កន្លងមក ហាក់ដូចជាច្របូកច្របល់បន្តិច ដូចជាពាក្យ ស្តុកស្តឹង, ផ្តិល(ទឹក), ផ្តាច់ផ្តិល ។ ប៉ុន្តែអ្នកប្រាជ្ញបានកំណត់ប្រើជើង(ត្ត) នៅផ្ញើពីក្រោមអក្សរ (ន) វាមានសំឡេងជាជើង(ត្ត)ទាំងអស់ដូចជា ប៉ុន្តែ, កន្ត្រៃ, កន្ត្រាំង, អន្តរាយ, បន្តិចបន្តួច ។ល។ លើកលែងតែពាក្យ ៤ ម៉ាត់ចេញ ដែលជើង (្ត) យកទៅផ្ញើនឹង (ន) ទៅជាមានសំឡេង «ដ» នោះគឺ **សន្តោស, សន្តាន, ចិន្តា, អន្តរធាន** ។ ប៉ុន្តែបើជើង (្ត) នៅផ្ញើនៅពីក្រោមតួព្យញ្ជនៈ (ណ) វិញនោះ វាមានសំឡេងជា «ដ» វិញ ដូចជា សណ្តែក, សណ្តាន់, កណ្តៀវ, កណ្តុរ, កណ្តាល, អណ្តូង, អណ្តើក [2] ។ល។

ខ/ ចំពោះជើង «**ញ**» បើកាលណាត្រូវយកជើង (ញ) ទៅផ្ញើនឹងព្យញ្ជនៈ (ញ) នោះ អក្សរ(ញ) ខាងលើត្រូវកំបុតជើង (ខ្នែង ្ញ) ។ រីឯជើង(ញ)ដែលយកទៅផ្ញើនឹងតួ (ញ) នោះ មានសិទ្ធិអាចរក្សាជើង (ខ្នែង ញ្ញ) នេះបាន ។ ឧទាហរណ៍ បញ្ញើក្អែក, បញ្ញត្តិ, អនុញ្ញាត, កញ្ញា, សញ្ញា ។

គ/ ជើង **ឡ** មិនដែលប្រើទេ

ឃ/ ជើង (្ព) និងជើង (្វ) អាចប្រើចូលគ្នាបាន ដោយយកជើង (្វ) ទៅផ្ញើពីក្រោមព្យញ្ជនៈ (ព) ដូចជា និព្វាន ។

**សូមគូសបញ្ជាក់ថា** បុព្វបុរសយើងផ្លាស់ប្តូរ (ពៈ) ជា (វៈ) គឺប្រើជាមួយគ្នាជំនួសគ្នាបាន ប៉ុន្តែគេមិនអាចយកជើង (ព) ទៅផ្ញើនឹងតួ (វ) ឡើយ ។

## ៦-អំពីវគ្គ

1. វគ្គ (ក) កខគឃង
2. វគ្គ (ច) ចឆជឈញ
3. វគ្គ (ដ) ដឋឌឍណ
4. វគ្គ (ត) តថទធន
5. វគ្គ (ប) បផពភម

ឯតួអក្សរទាំង៨តួដែលសល់ពីវគ្គទាំង៥ខាងដើមនោះ លោកហៅថា សេសវគ្គ បានដល់ ៖ យ រ ល វ ស ហ ឡ អ ។

## ៧-សំឡេងព្យញ្ជនៈ

ព្យញ្ជនៈ ៣៣តួនេះ ចែកចេញសំឡេងជាពីរប្រភេទគឺ ៖

1. **អឃោសៈ** បានដល់ព្យញ្ជនៈដែលមានសំឡេងតូចស្រួយ មិនលាន់ឮគឹកកង មានដូចជា កខ ចឆ ដឋណ តថ បផ សហឡអ (១៥តួ) ។
2. **ឃោសៈ** ពួកព្យញ្ជនៈដែលមានសំឡេងធំគ្រលរ គឹកកង ដូចជា គឃង ជឈញ ឌឍ ទធន ពភម យរលវ (១៨តួ) ។ ព្យញ្ជនៈសំឡេងឃោសៈ ប្រទាញស្រៈនិស្ស័យ ឲ្យឮសូរគ្រលរគឹកកងដូចវាដែរ ។

## ៨-ព្យញ្ជនៈប្ដូរសំឡេង

ដើម្បី មានពាក្យប្រើប្រាស់គ្រប់គ្រាន់ ទៅតាមពាក្យទាំងប៉ុន្មានក្នុងភាសាខ្មែរយើង បុព្វបុរសយើងបានកែច្នៃ បំប្លែងសំឡេងព្យញ្ជនៈខ្លះៗពីឃោសៈទៅជាសំឡេងអឃោសៈ ដោយយកសញ្ញាមូសិកទន្ត «៉» មកដាក់សម្លាប់ពីលើ ឧ. ង៉, ញ៉, ប៉, ម៉, យ៉, រ៉, វ៉ (៧តួ) ។ រីឯសញ្ញាត្រីសព្ទ (៊) នេះ លោកយកទៅដាក់ពីលើព្យញ្ជនៈអឃោសៈមួយចំនួនបំប្លែងសំឡេងឲ្យទៅជា ឃោសៈវិញ ដូចជា ៖ ប៊, ស៊, ហ៊, អ៊ (៤តួ) ។

### កំណត់សម្គាល់

អក្សរដែលដាក់សញ្ញាត្រីសព្ទ (៊) ហើយបើកាលណាមកជួបប្រទះនឹងស្រៈ ិ ី ឹ ឺ ើ នោះគេផ្លាស់ត្រីស័ព្ទចេញហើយដាក់ (ុ) ជំនួសវិញចៀសវាងការទើសទែងដូចជាពាក្យ ស៊ី

ហ៊ីហា ។ ឯពាក្យសម្លាប់ដោយធ្មេញកណ្ដុរ ក៏យក(ុ) មកជំនួសមូសិកទន្តដែរ ដូចពាក្យ ប៊ុន ប៊ុច [3] ។

ករណីពិសេស ក្នុងការសរសេរពាក្យ «**ប៉ិច**» ឈ្មោះ «**ប៉ិម**» គេមិនអាចអនុវត្តក្បួនខាងដើមនោះបានឡើយ ព្រោះបើយកស្រៈ «ុ» មកប្រើតាមក្បួនខាងលើ វាអាចច្រឡំនឹងពាក្យ «**ប៊ិច**» (ប៊ិចពន្លក) ឬទឹក «**ប៊ិម**» ហៀបនិងហូរចូលទូក ។

## ៩-ព្យញ្ជនៈផ្ញើជើង

**ផ្ញើជើង** គឺជាវិធីយកជើងព្យញ្ជនៈមួយ ទៅផ្សំជាមួយនឹងព្យញ្ជនៈមួយទៀត ដើម្បីបង្កើតបានជាសំឡេងផ្សំពីរបញ្ចូលគ្នា ឲ្យលាន់ឮក្នុងព្យាង្គតែមួយ ។ នៅក្នុងភាសាខ្មែរយើង សម្បូរពាក្យដែលផ្សំសំឡេងពីររួមបញ្ចូលមកតែមួយព្យាង្គ សម្រាប់អាននិយាយចេញមកភ្ជាប់គ្នាដូចជាសំឡេងភ្លោះ ។

ឧទាហរណ៍
ក+្ប = ក្ប មានក្នុងពាក្យ «ក្បាល»
ខ+្ស = ខ្ស មានក្នុងពាក្យ «ខ្សត់»

របៀបយកជើងទៅផ្ញើ (ផ្សំ) ជាមួយព្យញ្ជនៈ «**គោល**» គឺព្យញ្ជនៈមានឋានៈជាម្ចាស់មានរបៀបប្លែកគ្នា ៖

1. យកជើងផ្សំដាក់ពីក្រោមតួព្យញ្ជនៈគោល ៖ ខ្លី, ឆ្មា ។
2. យកជើងផ្សំដាក់ពីឆ្វេងតួព្យញ្ជនៈ ៖ ស្រែ ។
3. យកជើងផ្សំដាក់ពីក្រោមនិងខាងស្ដាំ ៖ សង្ឃ, អភិវឌ្ឍ, សប្បាយ, រក្សា ។

## ១០-ព្យញ្ជនៈបន្ថែម

ដើម្បី អាចសម្របតម្រូវជាមួយសំណូរម្យ៉ាងតាមបែបសូរសៀងជាភាសាបរទេស ដែលយើងតែងតែខ្ចីយកមកប្រើខ្លះៗ មានភាសាបារាំង អង់គ្លេស.... គេយកតួព្យញ្ជនៈមកផ្សំជាមួយជើងព្យញ្ជនៈ ដូចជាពាក្យ guitare= ហ្គីតារ, frein ហ្វ្រាំង, café =កាហ្វេ, George Cœdès= ហ្សឺក សេដែស [4] ។ល។

### ១១-សិថិល និង ធនិត

ក/ **សិថិល** គឺព្យញ្ជនៈដែលមានសំឡេងស្រាលប្រមូលផ្ដុំចេញសំឡេងដាច់តែមួយ ពុំមានខ្យល់ផ្សំពីព្យញ្ជនៈណាផ្សេង ៖ ក គ ច ជ ដ ឌ ត ទ ប ព ។

ខ/ **ធនិត** រាល់ព្យញ្ជនៈដែលមានគួបផ្សំដោយសំឡេង «ហ» មានដូចជា ខ< ក+ហ; ឆ< ច+ហ; ឋ< ដ+ហ; ថ< ត+ហ; ផ< ប+ហ; ឃ < គ+ហ; ឈ < ជ+ហ៊ ; ឍ < ឌ+ហ៊; ធ < ទ+ហ៊; ភ < ព+ហ៊ ។

### ១២-ព្យញ្ជនៈគូ

នៅក្នុងតួព្យញ្ជនៈទាំង ៣៣តួ ក្នុងវគ្គនីមួយៗ តែងតែមានព្យញ្ជនៈជាគូនឹងគ្នា ដែលមួយមានសំឡេង **អឃោសៈ** ហើយមួយទៀតមានសំឡេង**ឃោសៈ** គឺ ៖

1. **ផ្នែកអឃោសៈ** ៖ **ក** គូនឹង **ខ**; **ច** គូនឹង **ឆ**; **ដ** គូនឹង **ឋ**; **ត** គូនឹង **ថ** ។
2. **ផ្នែកឃោសៈ** ៖ **គ** គូនឹង **ឃ**; **ជ** គូនឹង **ឈ**; **ទ** គូនឹង **ធ**; **ព** គូនឹង **ភ** ។

ចំពោះព្យញ្ជនៈសេសគូ នៅចុងវគ្គទាំង៥ មាន **ង**, **ញ**, **ណ**, **ន**, **ម** និងព្យញ្ជនៈសេសវគ្គទាំង៨តួ មាន ៖ **យ រ ល វ ស ហ ឡ អ** នោះពុំមានគូទេ ។

# ផ្នែកទី ២

## វណ្ណយុត្តិ (Signe Diacritique)

**វណ្ណយុត្តិ** គឺ ជាសញ្ញាទាំងឡាយដែលបង្កើតឡើង ដើម្បីកែប្រែ ផ្ដួលសំឡេងព្យញ្ជនៈ ឬពាក្យពេចន៍ខ្លះ ឲ្យសមស្របទៅតាមតម្រូវការប្រើប្រាស់ ក្នុងភាសារបស់យើង ។ មិនតែប៉ុណ្ណោះ សញ្ញាទាំងនេះ ក៏អាចជួយបំប្លែងសំឡេងនៃពាក្យខ្លះ ដែលមានប្រភពមកពីភាសាបាលី ឬសំស្ក្រឹតផងដែរ ។

វណ្ណយុត្តិទាំងឡាយចែកចេញជាពីរពួកគឺ ៖

1. វណ្ណយុត្តិដែលបន្ថែមលើព្យញ្ជនៈ ដើម្បីលម្អៀងស័ព្ទឲ្យខ្លីឲ្យមានសូរផ្សេង ឲ្យប្លែកពីសំឡេងដើម (Signes diacritiques) ។
2. វណ្ណយុត្តិ ដែលប្រើជាមួយនឹងពាក្យក្នុងឃ្លាប្រកប ដើម្បីកាត់ឃ្លាជាប្រយោគជាសង្កាត់ ដើម្បីសម្គាល់ន័យសេចក្តីផ្សេងៗ ។ វណ្ណយុត្តិពួកនេះហៅថា «**ខណ្ឌសញ្ញា**» (Signe de ponctuation) ។

## ១-មូសិកទន្ត ឬធ្មេញកណ្ដុរ «៉»

ជាសញ្ញាប្រើសម្រាប់សម្លាប់, បំបែរសំឡេងព្យញ្ជនៈ **៧តួ** ដែលមានសំឡេងឃោសៈ ឲ្យទៅជាអឃោសៈ គឺ **ង, ញ, ប, ម, យ, រ, វ,** ឲ្យទៅជាសំឡេងអឃោសៈវិញ **ង៉, ញ៉, ប៉, ម៉, យ៉, រ៉, វ៉,** ។ ប្លែកតែតួ «**ប**» មួយ ដែលមានសំឡេងអឃោសៈស្រាប់ ប៉ុន្តែគ្រាន់តែលម្អៀងសូរពី **ប** ទៅ **ប៉** ប៉ុណ្ណោះ ។ អក្សរប្ដូរសំឡេងទាំងនេះ ត្រូវបានប្រើក្នុងពាក្យ ង៉ក់ង, ញ៉ៀងញ៉ង, ប៉ប៉ាច់ប៉ប៉ោច, ម៉ែឪ, យ៉ាប់យ៉ឺន, រ៉ឿងរ៉ាវ, វ៉ូងវ៉ាង ។

<u>**ចំណាំ**</u> ៖ កាល ណាពាក្យទាំងនេះទៅប្រទះនឹងស្រៈ ិ ី ឹ ឺ ើ ឧទាហរណ៍ ៖ ផ្ទះប៊ិត យ៉ាប់យ៉ឺន, ល្បែងចាប៊ីក... ។ គេត្រូវយកសញ្ញា (ុ) មកជំនួសធ្មេញកណ្ដុរ ដែលដាក់ពីលើ ដើម្បីកុំឲ្យវណ្ណយុត្តិនេះ ទើសទែងគ្នាជាមួយស្រៈខាងលើ ។ ឧទាហរណ៍ ស៊ី ប៊ើង រ៊ឹងប៊ឹង ។

## ២-ត្រីស័ព្ទ (៊) [5]

ជាសញ្ញាសម្រាប់ដាក់លើព្យញ្ជនៈ **៤តួ** ជាអឃោសៈ **ប, ស, ហ, អ,** ឲ្យទៅជាឃោសៈវិញ ៖ **ប៊, ស៊, ហ៊, អ៊,** ។ ព្យញ្ជនៈប្ដូរសំឡេងទាំងនេះ ត្រូវបានយកទៅប្រើក្នុងពាក្យ សាប៊ូ, សម្លស៊ុប, ហ៊ាន, ទ្រអ៊ូ... ។ កាលណាសញ្ញាត្រីស័ព្ទនេះជួបប្រទះនឹងស្រៈ ិ ី ឹ ឺ ើ ក៏ត្រូវប្រែប្រួលរូបមកជា (ុ) ដូចករណីខាងលើដែរ ឧទាហរណ៍ ស៊ីបាយ, លេងហ៊ី... លើកលែងតែពាក្យ ប៊ិច, អ៊ីចុះអ៊ីចឹង... ។

## ៣ របស្សសញ្ញា ឬបន្តក់ (់)

សម្រាប់ប្រើដាក់ថែមលើតួប្រកបនៃពាក្យ ដែលកើតឡើងពីស្រៈ «**អ**» និងស្រៈ «**អា**» ហើយកាត់ស័ព្ទវែងឲ្យទៅជាខ្លី ដែលត្រូវអានលឿនរហ័ស ។ ឧទាហរណ៍ ៖ កាត = ស័ព្ទវែង, កាត់ = ស័ព្ទខ្លី, ចប = ស័ព្ទវែង, ចប់ = ស័ព្ទខ្លី ។

## កំណត់សម្គាល់

1. ចំពោះតួព្យញ្ជនៈប្រកបនឹងអក្សរ «**ម**» ត្រង់សំឡេងប្រកបលំដាប់ទី២នោះ មិនបាច់ប្រើសញ្ញា «**រស្សៈ**» ឬបន្តក់ទេ ឧទាហរណ៍ ៖ ចាម់ ។ ក្នុងករណីនេះ គេប្រើនិគ្គហិត( ) ឬស្រៈ «ាំ» «**ចាំ**» ជំនួសវិញ ។
2. រីឯតួព្យញ្ជនៈប្រកបនឹងអក្សរ «**យ**» ត្រង់សំឡេងប្រកបលំដាប់ទី២នោះ ក៏មិនបាច់ប្រើ «**រស្សសញ្ញា**» ឬបន្តក់ដែរ, ដូចជាពាក្យ «**ចាយ់**» ក្នុងករណីនេះគេយកស្រៈ «ៃ» មកជំនួសវិញ ព្រោះមានសំឡេងដូចគ្នា ។
3. ចំពោះ ពាក្យទាំងឡាយណា ដែលក្លាយមកពីភាសាបាលីឬសំស្ក្រឹត មិនត្រូវប្រើសញ្ញា (់) នេះឡើយ ដូចជាពាក្យ បទ, សព, ភព, កុសល, ផល កិច្ចកល ធនធាន រសជាតិ លាមក ... ពាក្យទាំងនេះមានសំឡេងខ្លីស្រេចហើយ តាមទម្លាប់អានបែបបាលី និងសំស្ក្រឹត ។

## ៤-សំយោគសញ្ញា (័)

ក/ គេប្រើវណ្ណយុត្តិនេះសម្រាប់លម្អៀងស័ព្ទរបស់ពាក្យក្លាយមកពីភាសា បាលី ឬសំស្ក្រឹត ដូចជា ៖ ភយ > ភ័យ, ជយ > ជ័យ, នយ > ន័យ, អាស្រយ > អាស្រ័យ [6], អាលយ > អាល័យ ។

ខ/ សញ្ញានេះក៏ប្រើលើពាក្យខ្មែរខ្លះ ដែលមានសំឡេងស្មើរស្រៈ «**អ**» និង ស្រៈ «**អា**» ដើម្បីឲ្យមានសូរសំឡេងមួយត្រូវចំនឹងសំឡេងពិតនៃពាក្យនោះ គឺ ញ័រ, ជ័រ, ទំព័រ... ។

គ/ សម្រាប់ប្រើសម្រួលសំឡេងក្លាយពីពាក្យបរទេសខ្លះៗ ដូចជា ដុកទ័រ, ប៉ាស្ទ័រ, អាំងហ្សេនីញ័រ, កុំព្យូទ័រ, ត្រាក់ទ័រ [7] ។

## ៥-របាទ (៌)

វណ្ណយុត្តិនេះ ជាតំណាងអក្សរ «**រ**» ដែលគេកាត់យកក្បាលខាងលើរបស់វា មករក្សាទុកធ្វើជាសញ្ញារបាទ (៌) ។ គេប្រើវណ្ណយុត្តិនេះ សម្រាប់ដាក់លើពាក្យដែលក្លាយមកពីភាសាសំស្ក្រឹត ដើម្បីសម្រួលសំឡេងអានតាមបែបសំឡេងខ្មែរ ។ គេកត់សម្គាល់ថា ពាក្យបាលីណា ដែលសរសេរតម្រួតនោះ កាលណាយើងសរសេរជាពាក្យសំស្ក្រឹតក្លាយខ្មែរ គេត្រូវដាក់ (៌) របាទនេះជំនួសវិញ ។

| បាលី | សំស្ក្រឹត និងសំស្ក្រឹតក្លាយ | បាលី | សំស្ក្រឹត និងសំស្ក្រឹតក្លាយ |
|---|---|---|---|
| វណ្ណ, ពណ្ណ: | ពណ៌ | បរិបុណ្ណ: | បរិបូណ៌ |
| ធម្ម: | ធម៌ | សម្បុណ្ណ | សម្បូណ៌ |
| សុវណ្ណ: | សុវណ៌, សុពណ៌ | វិសជ្ជនីយ | វិសជនីយ |
| សគ្គ | ស្វគ៌, សួគ៌ | សិទ្ធត្ថ | សិទ្ធាថ៌ |
| សព្វង្គកាយ | សព៌ាង្គកាយ | បព្វត | បព៌ត |

## ៦-អស្តា (៏)

វណ្ណយុត្តិនេះ គឺមានទ្រង់ទាយជាលេខ «៨» ប៉ុន្តែបង្រួញឲ្យតូច ដើម្បីងាយយកមកដាក់លើព្យញ្ជនៈ «ក» និង «ដ» ដែលជានិបាតស័ព្ទ ។ ឧទាហរណ៍ ៖ ខ្ញុំក៏ទៅ, អ្នកក៏ទៅ, ទោះបីយ៉ាងណាក៏ដោយ ...។ ក្រៅពីនេះគេប្រើលេខអស្តា សម្រាប់ដាក់លើពាក្យឧទានស័ព្ទខ្លះ ជាពាក្យភ្ញាក់ស្មើច រំភើប... ឱហ្ន៏ នុ៎ះហ្ន៏ ។

## ៧-ទណ្ឌឃាត ឬបដិសេធ (៍)

វណ្ណយុត្តិនេះ មានរូបសណ្ឋានដូចសក់លេខ «៩» ។ គេប្រើទណ្ឌឃាត ដើម្បីដាក់លើអក្សរព្យញ្ជនៈណា ដែលគេមិនអាន ប៉ុន្តែគេត្រូវតែរក្សាទុកព្យញ្ជនៈនោះជាចាំបាច់ ក្នុងន័យរក្សាអក្ខរាវិរុទ្ធរបស់ពាក្យ និងជាគ្រឿងសម្គាល់ជាតិស័ព្ទរបស់ពាក្យ ។ ឧទាហរណ៍ ៖ ទូរទស្សន៍, ប្រយោជន៍, គមនាគមន៍, ព្រឹត្តិការណ៍, ពាក្យពេចន៍, វេយ្យាករណ៍, ត្រ័យរតន៍ ។ គេច្រើនប្រើទណ្ឌឃាតលើពាក្យក្លាយពីបាលីនិងសំស្ក្រឹត ។ សញ្ញានេះ ក៏យកមកប្រើចំពោះពាក្យខ្ចីពីបរទេសខ្លះ សម្រាប់រក្សាលំនាំអក្ខរាវិរុទ្ធដើមរបស់ពាក្យទាំងនោះ ដូចជា ស៊ីម៉ងត៍, អេដស៍, អាល់ប៊ែរត៍... ។

## ៨-វិសជ្ជនី (ះ) ឬរះមុខ

គេប្រើសញ្ញានេះ សម្រាប់ប្រកបជំនួសខ្យល់ «ហ» ជាពាក្យកាត់កំបុតខ្លី ហើយអានដោយបើកចំហមាត់ដូចជា តិះ, រិះ, ចុះ, ចង្កើះ (ចង្កឹះ) ឈ្មោះ, ទះ, ដោះដូរ, លោតផ្លោះ ។ល។ វាមានសូរសំឡេងស្រដៀងនឹងពាក្យដែលប្រកបនឹងព្យញ្ជនៈ «ស» ដែរ ។

## ៩-យុគលពិន្ទុ(ៈ) ឬហៅថា “ ចុចពីរ ” ក៏បាន [8]

គេប្រើវណ្ណយុត្តិនេះសម្រាប់ ៖ ដាក់នៅចុងពាក្យមានកំណើតពីបាលី ឬសំស្រ្កឹត ដែលមានសូរ «**អាក់**» ឬ «**អ៊ាក់**» ដូចជា លោភៈ, មោហៈ, ទោសៈ...

**ចំណាំ** ៖ បើពាក្យទាំងនេះនៅខាងដើមគេ ដូចជា ពលកម្ម, វណ្ណកម្ម សច្ចភាព, ខេមរភាសា នោះគេមិនចាំបាច់ដាក់យុគលពិន្ទុទេ ព្រោះពាក្យទាំងនេះជាសមាសនាម ។

**លើកលែងតែពាក្យ** ៖ គណៈ ដែលទោះបីវានៅដើមគេ ឬកណ្ដាលគេក្ដី ក៏ត្រូវតែប្រើយុគលពិន្ទុជាដរាប ឧទាហរណ៍ គណៈប្រតិភូ, គណៈកម្មការ, គណៈសង្ឃ, គណៈរដ្ឋមន្ត្រី, គណៈប្រធានរដ្ឋ... ព្រោះថាក្នុងពាក្យទាំងនេះ «**គណៈ**» មិនចូលក្នុងសមាសនាមតាមក្បួនខ្នាតវេយ្យាករណ៍បាលី ។

**លើកលែងតែពាក្យ** ៖ គណបក្ស, គណនា, គណនេយ្យ... ដែលគេមិនត្រូវប្រើយុគលពិន្ទុទេ ។

**រីឯពាក្យ** ៖ **កាលៈទេសៈ** គេត្រូវប្រើយុគលពិន្ទុកទាំងពីរម៉ាត់តែម្ដង ។ ក៏ប៉ុន្តែ បើគេសរសេរពាក្យនេះ «**បញ្ច្រាស**» មកវិញ «**ទេសកាល**» នោះ គេមិនត្រូវប្រើយុគលពិន្ទុឡើយ ។

ក្នុង សម័យនេះ គេយកយុគលពិន្ទុមកប្រើក្លាយក្នុងឃ្លាប្រយោគខ្លះដែរ សម្រាប់រាប់រាយឈ្មោះអ្វីៗ ដូចពាក្យថា ទង់ជាតិបារាំងមាន ៣ពណ៌គឺៈ ស, ខៀវ, ក្រហម ។ ប៉ុន្តែជាទូទៅ អ្នកនិពន្ធទាំងឡាយតែងតែប្រើ «**ទ្វិពិន្ទុលេខ**» ក្នុងករណីរៀបរាប់, ឧទ្ទេស បង្ហាញ... ព្រោះការប្រើសញ្ញាខណ្ឌបែបនេះត្រឹមត្រូវ និងសមហេតុសមផលជាង ។ យើងនឹងបានឃើញព្រមទាំងអធិប្បាយពន្យល់ អំពីខណ្ឌសញ្ញានេះនៅទំព័រខាងមុខ ។

## ១០-វជ្ជសញ្ញា ឬសហសញ្ញា (-) “Trait d’union”

ជាសញ្ញាបន្ទាត់ផ្ដេកខ្លីសម្រាប់ប្រើប្រាស់បានច្រើនយ៉ាងនៅក្នុងការសរសេរអត្ថបទ ឬតែងនិពន្ធជាដើម ។

1. សម្រាប់បំបែកព្យាង្គនៃពាក្យមួយ កុំឲ្យអានច្រឡំជាប្រកប នាំឲ្យខុសពាក្យដូចជា ទូក-ង, កុក-ស, សម្បុរ-ស,ខ្សែ-ក...។

2. សម្រាប់តភ្ជាប់ពាក្យមួយ ដែលសរសេរមិនទាន់ចប់នៅចុងទំព័រ ហើយត្រូវត្រឡប់មកសរសេរនៅដើមបន្ទាត់វិញ ។
3. សម្រាប់ភ្ជាប់ពាក្យមួយដែលដាច់គ្នា ដើម្បីតម្រូវចាប់ចុងចួនក្នុងកំណាព្យ ។
4. សម្រាប់បញ្ជាក់អំពីការផ្លាស់ប្តូរឃ្លាសន្ទនានៃតួពីរ ឬច្រើននាក់ ។
5. សម្រាប់សម្គាល់នូវការរៀបរាប់ ជាលំដាប់លំដោយ អំពីគំនិត ឬចំណុចប្លែកៗ ។

## ១១-កាកបាទ ឬជើងក្អែក (+)

គឺ ជាបន្ទាត់ខ្លីពីរ មួយផ្តេកមួយទៀតបញ្ឈរ គូសកាត់ខ្វែងគ្នាចំពាក់កណ្តាល ។ គេប្រើវណ្ណយុត្តិនេះ សម្រាប់ដាក់លើពាក្យឧទានស័ព្ទខ្លីៗមួយចំនួន ដែលមានសូរសៀងបង្អូស ឬត្អូញថ្ងូរ ដូចជាពាក្យ ចា៎ះ ! បា៎ទ ! ណា៎ ! ហ៎្ន, នុ៎ះ, ណ៎ះ, អ៊ូ៎, អ្ហា៎... ។ ខាងផ្នែកនព្វន្ត គេប្រើសញ្ញាជើងក្អែកជាសញ្ញាបូក, ឧទាហរណ៍ ៖ ១៥+៣៨ ។

## ១២-លេខទោ (ៗ)

សញ្ញានេះគេប្រើសម្រាប់

1. ផ្ទួនពាក្យដែលតម្រូវឲ្យថា ឬអានពីរដង,
2. សម្រាប់បញ្ជាក់អំពីចំនួនច្រើន ឬ ពហុវចនៈ ។

**ចំណាំ** ៖ មិន មែនកំណត់ថា គ្រប់តែពាក្យដែលត្រូវថាឬអានពីរដងនោះ ត្រូវតែដាក់លេខទោទាំងអស់នោះ ទេ ។ ពាក្យបាលីខ្លះដែលយកមកប្រើក្នុងភាសាខ្មែរ ដូចជា នានា ធម្មសង្វេគ គេត្រូវសរសេរពាក្យ «**នានា**» នេះត្រួតគ្នាពីរដង ដោយគោរពទៅតាមវិធានបាលី ។ ដូចជាពាក្យថា ឯហិមម...? ។ បើប្រើជាមួយគុណនាម និយាយអំពីពណ៌នោះ ពាក្យស្ទួនដោយប្រើលេខទោ ចង់បញ្ជាក់អំពីប្រភេទពណ៌ ដោយឡែកៗរបស់វត្ថុ ។

ចំពោះ ពាក្យខ្មែរខ្លះ ដែលមានសំឡេងដដែលៗពីរដងដូចជាបបរ កករ ត្រូវតែសរសេរពីរដងជាន់គ្នាដូច្នេះជាដរាប ។ ហាមដាច់ខាត មិនឲ្យសរសេរ បរៗ,ករៗ, បែបនេះឡើយ ។

1. លេខទោប្រើក្នុងករណីបញ្ជាក់ និងប្រៀបធៀប ។
2. លេខទោប្រើជាមួយពាក្យមួយព្យាង្គ ។
3. លេខទោប្រើជាមួយពាក្យពីរម៉ាត់ ។

4. លេខទោប្រើជំនួសពាក្យបីម៉ាត់ឬច្រើនព្យាង្គ ។

**ចំណាំ** ៖ លេខ ទោមិនអាចប្រើផ្ទួនបាននៅខាងចុងពាក្យពិពណ៌នា អំពីរូបរាងមនុស្សឬសត្វ ដូចជា កូនគោនេះធាត់ទ្រលុកលុក មុខឡើងកំប្លង់ប្លង់ដូចរង់ចន្ទ្រា ។ ស្គមកំព្រឹងព្រឹង ។ មិនត្រូវប្រើលេខទោនេះក្នុងករណីប្រើពាក្យដដែលច្រើនដង ។

# ផ្នែកទី៣

## ខណ្ឌសញ្ញា (Signes de ponctuation)

**ខណ្ឌសញ្ញា** គឺជាសញ្ញាមានរូបភាពប្លែកៗ សម្រាប់ប្រើក្នុងការសរសេរអត្ថបទផ្សេងៗ ដើម្បីសម្គាល់លក្ខណៈ ទម្រង់បែបបទ ដែលជាលំនាំឲ្យងាយយល់ ឲ្យអានបានត្រឹមត្រូវ ។

### ១-ក្បៀស (,) ឬកណ្ដកសញ្ញា (La virgule) [9]

សញ្ញា នេះ ប្រើសម្រាប់ញែកពាក្យក្នុងប្រយោគឲ្យដាច់ពីគ្នា ទោះពាក្យរៀបរាប់នោះ ជានាមក្ដី ជាគុណនាមក្ដី ជាកិរិយាស័ព្ទក្ដី ។ គួរកត់សម្គាល់ថា ការប្រើក្បៀសក្នុងការសរសេររបស់ខ្មែរយើង ក៏ប្រហាក់ប្រហែលនឹងការប្រើក្បៀសរបស់លោកខាងលិចដែរ ។

1. ការប្រើក្បៀសក្នុងការពិពណ៌នា រៀបរាប់ជំពូកនាម
2. ការពិពណ៌នារៀបរាប់អសាធារណនាម
3. ការពិពណ៌នារៀបរាប់គុណនាម
4. ការពិពណ៌នារៀបរាប់កិរិយាស័ព្ទ

**កំណត់សម្គាល់**

នៅ ក្នុងឃ្លាប្រយោគបរទេសដូចជា ភាសាបារាំង អង់គ្លេស អេស្ប៉ាញ៉ុលជាដើមនោះ ប្រយោគល្បះណាដែលខ្មែរយើងត្រូវប្រើដកឃ្លា គេប្រើក្បៀសទាំងអស់ ។ នេះអាចជាទម្លាប់ភាសាគេ ឬក៏ធ្វើទៅតាមការតម្រូវចាំបាច់ នៃក្បួនវេយ្យាករណ៍របស់គេ ។

អត្ថបទ ខ្មែរយើងពីបុរាណ ដែលចារនៅលើក្រាំងក្តី សាស្ត្រាស្លឹករឹតក្តី នៅក្នុងឃ្លាប្រយោគទាំងអស់នោះ ពុំដែលមានប្រើក្បៀសទាល់តែសោះ ។ យើងកត់សម្គាល់ឃើញថា ចាប់តាំងពីប្រទេសយើង ឋិតក្រោមរបបអាណានិគមបារាំងមក ប្រហែលដោយសារបានទទួលឥទ្ធិពលពីរបៀបរបបសរសេរបែបបារាំង យើងក៏ចាប់ផ្តើមប្រើក្បៀសជារៀងរហូតមក ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី យើងសង្កេតឃើញមានទំនោរពីរគឺ ៖

1. ប្រភេទជនដែលបានរៀនសូត្រចេះដឹងជ្រៅជ្រះភាសាបារាំង ច្រើនសរសេរប្រើក្បៀស ។
2. ប្រភេទជនដែលចេះតែភាសាខ្មែរ ក៏ទទួលយកទម្លាប់មត៌កពីបុព្វបុរសជាន់ដើម ហើយសរសេរឥតប្រើក្បៀសទេ ។

និយាយរួមមក ការប្រើដកឃ្លា ជំនួសក្បៀស ឬប្រើដកឃ្លាផង និងប្រើក្បៀសផង គឺមិនមានអ្វីប្លែកគ្នាខ្លាំងពេកនោះទេ ។ ប៉ុន្តែការប្រើក្បៀស វាមានចរិតច្បាស់លាស់ប្រាកដប្រជាជាង [10] ។

## ២-ទ្វិពន្ទុលេខ ឬ ចំណុចពីរគូស (៖)

សញ្ញាដែលមានគំនូសផ្តេកនៅខណ្ឌចន្លោះសូន្យពីរ លើមួយក្រោមមួយនេះ គេប្រើសម្រាប់ ៖

1. ដាក់ នៅចុងបញ្ចប់នៃប្រយោគ ក្នុងន័យកត់ត្រាសម្តីរបស់បុគ្គលណាមួយ ដែលគេស្រង់យកមកដាក់ក្នុងសញ្ញាអញ្ញប្រកាស(“ ”) គេកត់សម្គាល់ឃើញថា សញ្ញាបែបនេះ ច្រើនតែប្រើក្នុងទម្រង់រចនាបថប្រយោគពណ៌នាក្នុងរឿងព្រេង, រឿងនិទាន, ការនិយាយប្រាប់គ្នាពីហេតុការណ៍អតីតកាល ។ល។
2. សម្រាប់ដាក់នៅចុងប្រយោគណា ដែលត្រូវបន្តទៅដល់ការរៀបរាប់ ដោយចាត់ជាពួក, ជាផ្នែក ។

### កំណត់សម្គាល់

មិន ត្រូវច្រឡំយុគលពិន្ទុ (ះ) ជាមួយនិងទ្វិពិន្ទុលេខ (៖) ទេ ។ យុគលពិន្ទុ គ្រាន់តែចុចចំណុចពីរលើក្រោមប៉ុណ្ណោះ, រីឯទ្វិពិន្ទុលេខ គឺមានសូន្យលើ (°) សូនក្រោម (°) ហើយមានរជ្ជុសញ្ញាខណ្ឌចំកណ្តាល គឺយ៉ាងនេះ (៖) ។ សព្វថ្ងៃនេះ យើងឃើញគេប្រើយុគលពិន្ទុតាមបែបអឺរ៉ុបជំនួសទ្វិពិន្ទុលេខ ដោយមកពីទម្រង់ពុម្ពអក្សរលីម៉ុន (font Limon) ពុំមានសញ្ញាទ្វិពិន្ទុលេខ ក៏

តាំងតែយកយុគលពិន្ទុមកប្រើជំនួសឲ្យតែបានៗសិន រង់ចាំអ្នកបច្ចេកទេសរកឃើញសញ្ញាទិ្វពិន្ទុលេខ នោះនឹងយកមកប្រើឲ្យបានត្រឹមត្រូវតាមវិធានវេយ្យាករណ៍ ។

ប៉ុន្តែគេអាចប្រើយុគលពិន្ទុបាន នៅក្នុងទម្រង់លិខិតខ្លះៗដូចជា កម្មវត្ថុ [11] ៖ ស្នើសុំអាហារូបករណ៍ទៅសិក្សានៅប្រទេសជប៉ុនយោងៈ លិខិតលេខ... ចុះថ្ងៃទី....

កំណត់សម្គាល់អំពីការប្រើ ឬមិនប្រើយុគលពិន្ទុនៅពីមុខពាក្យ «**ថា**» ៖

1. មិនប្រើយុគលពិន្ទុ ចំពោះតែពាក្យ «ថា[12]» ណាដែលជានិបាតស័ព្ទ ដែលអាចប្រៀបនឹងភាសាបារាំងថា “Que” បានដល់ពាក្យដែលត្រូវកត់ត្រាសម្ដីមិនផ្ទាល់របស់តួអង្គមាននិយាយក្នុង “Style indirect” របស់ភាសាបារាំង ដូចជាពាក្យ ៖ ពោលថា, និយាយថា, ទំនាយទាយថា, តិះដៀលថា, ជេរថា, ប្រាប់ថា... ពាក្យទាំងនេះ គេមិនត្រូវប្រើដាក់យុគលពិន្ទុ (ៈ) ពីមុខទេ ។
2. ត្រូវប្រើយុគលពិន្ទុ គេប្រើសញ្ញាយុគលពិន្ទុ (ៈ[13]) ក្នុងករណីកត់ត្រាពាក្យសម្ដីផ្ទាល់របស់អ្នកនិពន្ធ ត្រូវគ្នានឹងទម្រង់របស់ភាសាបារាំងថា (Style direct) ។

## ៣-បុច្ឆនសញ្ញា (?) (Point d'interrogation)

ជា សញ្ញាប្រើសម្រាប់ដាក់ពីខាងក្រោយពាក្យ, ឃ្លា, ល្បះ ចោទសួរជានិច្ច ។ នៅក្នុងពាក្យ, ល្បះ, ឃ្លា, ប្រយោគដែលចោទសួរ គេតែងប្រើជាចាំបាច់នូវពាក្យ ឬរូបមន្តផ្សេងមានជាអាទិ៍ៈ តើ, ព្រោះអ្វី, ហេតុអ្វី, ដូចម្ដេច, (ក៏, ឬ, បានជា...) យ៉ាងម៉េចក៏..., អ្វីទៅ, ស្អីគេ, អង្កាល់, កាលណា, ... ។ល។ ពាក្យសម្រាប់សួរអាចនៅដើមឃ្លា ឬ នៅចុងឃ្លាក៏បាន ។ ជួនកាលគេមិនចាំបាច់ ប្រើពាក្យសួរ គេគ្រាន់តែដាក់បុច្ឆនសញ្ញាទៅក៏បានដែរ ។

- ល្បះ, ឃ្លា, ពាក្យសំណួរខ្លីៗ ៖ ឃ្លានអ្វី? ម៉េចក៏យំ? ទៅសាលា? ដើរ? ជិះកង់ ?
- គប្បីកត់សម្គាល់ថា សំណួរដដែលគ្រាន់តែផ្លាស់ប្ដូរដាក់ពាក្យណាមុន ពាក្យណាក្រោយ ក៏ឲ្យន័យ ឬ រំលេចន័យខុសគ្នាដែរ ។

ក្រៅ ពីនេះ រាល់សំណួរដែលសុទ្ធតែមានបុច្ឆនសញ្ញានៅចុងល្បះដូចគ្នានេះ អាចមានន័យខុសប្លែកគ្នា ទៅតាមសំឡេងលើកដាក់ថ្នាក់ថ្នម គំហកកំហែង អង្វរករលន់តួ ។

មានបុច្ឆនសញ្ញមួយបែបទៀត ដែលច្រើនឃើញប្រើនៅក្នុងរូបគំនូរកំប្លែង (Caricature) ។

## ៤-ឧទានសញ្ញា (!) (Point d'exclamation)

សញ្ញា បង្គោលបញ្ឈរដែលមានចំណុច (!) មួយនៅពីក្រោមនេះ គេប្រើសម្រាប់ដាក់នៅពីក្រោយ ពាក្យ ឃ្លា ល្បះ ភ្ញាក់ផ្អើលតក់ស្លុត ស្ញើច ភ័យ អាសន្ន ខ្លាច បញ្ជាដាច់ខាត បែបទ់អធិដ្ឋាន សម្រែកជយឃោស គំរាមកំហែង ។ ជួនកាលគេក៏ប្រើឧទានសញ្ញាជាមួយនឹងឃ្លាកំហឹង បន្ទោស ឬ ជេរផងដែរ ។

## ៥-អញ្ញប្រកាស[14] (“...”)

គឺ ជាសញ្ញាឃ្នាបម្យ៉ាង ដែលនៅខាងដើមមានរាងកោងខ្វឹកកួចពីរឡើងទៅលើ ឯខាងចុងជាសញ្ញាខ្វឹកពីររាងកោង កួចទម្លាក់ចុះក្រោម ។ គេប្រើសញ្ញានេះសម្រាប់៖

1. គាប ឬកត់ត្រាដកស្រង់សេចក្តីសំខាន់របស់ជនណាម្នាក់ ទុកជាសេចក្តីពិសេសដោយឡែក ជាការរំលេច ឬបញ្ជាក់ឲ្យប្លែកពីន័យរបស់បរិបទ ។
2. ដកស្រង់គំនិត, សម្តីរបស់តួអង្គណាមួយក្នុងរឿង ។
3. ដកស្រង់តួអង្គណាមួយ ដែលមានកិត្តិស័ព្ទល្បីល្បាញ ។
4. ដកស្រង់សេចក្តីឬអត្ថន័យមានលក្ខណៈលេចធ្លោ ។

## ៦-អព្ភន្តរសញ្ញា[15] (‘...’)

សញ្ញា នេះ ខុសប្លែកពីអញ្ញប្រកាស ដោយប្រើតែខ្វឹកសញ្ញាមួយនៅខាងដើម និងក្បៀសសញ្ញាមួយនៅខាងចុង ។ របៀបប្រើនសអព្ភន្តរសញ្ញាខុសគ្នាបន្តិច ពីសញ្ញាអញ្ញប្រកាសដោយប្រើអព្ភន្តរសញ្ញាជាឃ្នាបពាក្យបិតនៅក្នុងរង្វង់ផែនពាក្យ ដែលដាក់ឃ្នាបដោយសញ្ញាអញ្ញប្រកាស ។

**សូមអនុញ្ញាតជម្រាបថា៖** នៅ ក្នុងសៀវភៅឯកសារជាទូទៅ គេកម្រឃើញអ្នកនិពន្ធប្រើសញ្ញានេះណាស់ ។ ជួនកាលគេប្រើអព្ភន្តរសញ្ញា ឬអញ្ញប្រកាស ក្នុងគោលដៅតែមួយដូចគ្នា ។ នៅក្នុងសៀវភៅវេយ្យាករណ៍របស់លោក **ពូវ អ៊ុម** លោកចាត់ទុកអព្ភន្តរសញ្ញាថា ជាសញ្ញាអញ្ញប្រកាស (សៀវភៅវេយ្យាករណ៍ ពូវ អ៊ុម ទំព័រ ៨) ចំណែកនៅក្នុងវចនានុក្រមសម្តេច**ជួនណាត** ទំព័រ ១៦៥៦-៥៧ វិញ ក៏បង្ហាញអព្ភន្តរសញ្ញា “ ....” មានរូបសណ្ឋានយ៉ាងនេះដែរ ។ លោកបានពន្យល់ពាក្យអព្ភន្តរសញ្ញាយ៉ាងនេះថា ៖ ពាក្យសន្មតហៅវណ្ណយុត្តិ ដែលពួកវេយ្យាករណ៍

បណ្ឌិតក្នុងប្រទេសអឺរ៉ុប បង្កើតឡើងសម្រាប់ប្រើរាំងពាក្យ ឬសេចក្តីមានរូបសណ្ឋានពីរបែបគឺ (“...”) ឬ («...»)[16] ។

ដូច្នេះ ដោយយល់ឃើញថា កិច្ចការសរសេរតែងនិពន្ធនាពេលបច្ចុប្បន្ននេះ មានសភាពល្អិតល្អន់ស៊ីជម្រៅ និងហ្មត់ចត់ យើងគួរតែបញ្ចូលអព្ភន្តរសញ្ញា ដែលមានរូបសណ្ឋានបែបនេះ (‘...’) មកប្រើបន្ថែមទៀត ដោយបំបែកចេញពីអញ្ញប្រកាស (“...”) ។

## ៧-មច្ឆណ្ឌសញ្ញា ឬ ពងត្រី (...) (point de Suspension)

ជួន កាលគេហៅថា (ចំណុចរាយ) ផងក៏មាន ។ សញ្ញាដែលមានចំណុចបីបន្តបន្ទាប់ជាប់គ្នានេះ សម្រាប់សម្គាល់ប្រយោគណាមួយ ដែលនៅមានសេចក្តីបន្តទៀត ប៉ុន្តែអ្នកសរសេរបានផ្អាកបញ្ឈប់លែងពណ៌នា ដោយដាក់សញ្ញាពងត្រីនេះ ប្រាប់ជាដំណឹង ។ របៀបប្រើពងត្រីមានបែបផែនប្លែកៗដូចតទៅ ៖

1. ជាសញ្ញាកាត់ពាក្យសម្តីតួសន្ទនាម្នាក់ ដែលកំពុងនិយាយឲ្យដាច់កណ្តាលឃ្លា ។
2. ជា សញ្ញាសម្រាប់ផ្អាកពាក្យសម្តី មិនចង់និយាយបន្តដោយទុកឲ្យតួសន្ទនាយល់ ឬក៏បង្កប់ទុកនូវពាក្យគំរាមកំហែង ពាក្យបណ្តាសា... ។
3. ផ្អាកសេចក្តីត្រឹមប៉ុណ្ណឹងសិន ឬស្លេះទុក ដោយមិនចង់ឲ្យសេចក្តីមានន័យដូចគ្នានេះវែងអន្លាយពេក ។
4. សម្រាប់ប្រាប់អំពីពាក្យឃ្លា ដែលបាត់រលុបមានសេចក្តីមិនច្បាស់ ដកយកចេញពីសិលាចារឹកជាដើម ។

## ៨-វង់ក្រចក ឬនខសញ្ញា ()

បានជាគេឲ្យឈ្មោះដូច្នេះ ព្រោះវាមានសណ្ឋានរាងកោងដូចវង់ក្រចកយើងពិតៗ ។ គេប្រើសញ្ញាវង់ក្រចកសម្រាប់ ៖

1. គាបពាក្យ ឬសេចក្តី ដែលគេចង់ពន្យល់ន័យ ។
2. គាបពាក្យដែលសរសេរជាអក្សរកាត់ ។

## ៩-វង់តង្កៀប [.....]

នៅ ក្នុងភាសាខ្មែរគេមិនស្រូវប្រើសញ្ញាវង់តង្កៀបនេះទេព្រោះយើង មានវណ្ណយុត្តិ និងខណ្ឌសញ្ញាយ៉ាងច្រើន សមស្របនឹងប្រើក្នុងអត្ថបទជាភាសាខ្មែរគ្រប់គ្រាន់អស់ហើយ ។ ប៉ុន្តែនៅក្នុងការគណនាលេខផ្នែកពីជគណិត (Algèbre) យើងយកមកប្រើតាមពួកអឺរ៉ុប ។

## ១០-រ៉ាត់ ឬឃ្នាប (} ឬ { ....}) (Accolade)

សញ្ញានេះ ខ្មែរខ្លះហៅថា ពុកមាត់មេអំបៅ ។

1. នៅ ក្នុងមុខវិជ្ជាពីជគណិត របៀបប្រើឃ្នាប ឬរ៉ាត់មានន័យដូចគ្នា នឹងការប្រើតង្កៀប ឬវង់ក្រចកដែរ ។ គេតែងតែប្រើរ៉ាត់មួយសម្រាប់បើក ({) និងរ៉ាត់មួយទៀតសម្រាប់បិទ (}) គឺបែបនេះ {.....} ។
2. រ៉ាត់បើក និងរ៉ាត់បិទនេះ ប្រើសម្រាប់គាបពាក្យពីរ ឬច្រើនជាការសម្គាល់ថា ពាក្យទាំងនោះមានមុខងាររួមដូចគ្នា មិនបាច់សរសេរដដែលច្រើនដងនាំខាតពេល ។

## ១១-បេយ្យាលៈ ឬ លៈ (។ល។)

គេ មិនសូវអានថា បេយ្យាលៈទេ ព្រោះវែងពេក គេអានកាត់យកតែខាងចុងត្រង់សូរថា ឡាក់, ឡៈ សរសេរថា ៖ (។ល។) ត្រូវនឹងពាក្យបារាំងថា (et cetera) សរសេរអក្សរកាត់ថា (etc.) ។ គេប្រើសម្រាប់បំព្រួញសេចក្តីឯណានីមួយ ឬការរៀបរាប់ដែលវែងឲ្យនៅខ្លី ដោយគិតថា អ្នកអានក៏ដឹងថា នៅមានពាក្យ និងសេចក្តីអ្វីខ្លះទៀត ។

## ១២- ខណ្ឌ ឬ ខណ្ឌសញ្ញា (។)

គេ ប្រើសញ្ញាខណ្ឌនេះ សម្រាប់រាំងខាំងប្រយោគ ឬសង្កាត់នៃសេចក្តីនីមួយៗ ឲ្យដាច់ស្រឡះពីគ្នា ។ កាលណាប្រយោគមួយចាប់សេចក្តីហើយ គេត្រូវដាក់សញ្ញា (។) នេះ មុននឹងបន្តទៅប្រយោគមួយទៀត ។ ខណ្ឌសញ្ញា ធ្វើឲ្យគេងាយយល់ អាចញែកសេចក្តីពីប្រយោគមួយទៅប្រយោគមួយ មិនឲ្យច្រឡំន័យ នាំច្របូកប្របល់ ។ ហើយនៅចន្លោះ ខណ្ឌសញ្ញា ការដកឃ្លាក៏ជួយសម្រួលឲ្យអ្នកអានងាយយល់ ងាយចាប់សេចក្តីបាន ។ មានតែការប៉ិនប្រសប់របស់អ្នកសរសេរតែងនិពន្ធទេ ដែលអាចយល់ដឹងដល់ការចាំបាច់នៃការដកឃ្លា ការដាក់ខណ្ឌសញ្ញាឲ្យបានត្រឹមត្រូវទេ ទើបធ្វើឲ្យអត្ថបទមានតម្លៃ មានន័យគួរជាទីចាប់អារម្មណ៍ ។

ប៉ុន្តែ កាលណាគេត្រូវប្តូរគំនិតចូលទៅវគ្គ ឬកថាខណ្ឌថ្មីនោះ គេត្រូវដាក់សញ្ញាខណ្ឌទៅចុងបញ្ចប់ប្រយោគ រួចហើយត្រូវចាប់សរសេរដោយចុះទៅបន្ទាត់ថ្មី ជាមួយនឹងការចោលលំហបន្តិចដែលគេតែងនិយមហៅថា ខណ្ឌ ចុះបន្ទាត់ឬចោលបន្ទាត់ និងចាប់ដើមបន្ទាត់ (នេះជាការប្រាប់ដំណឹងរបស់អ្នកហៅសរសេរតាមសូត្រ) ។

## ១៣- ខណ្ឌចប់ (៕)

ជាសញ្ញាសម្រាប់ដាក់បញ្ចប់អត្ថបទ ឬរឿងមួយតែត្រឹមនេះពុំមានតសេចក្តី ឬរឿងរ៉ាវទៅមុខទៀតឡើយ ។

## ១៤- អាទិសង្កេត (.)

គឺ ជាចំណុចមួយដែលដាក់ពីមុខអក្សរ ដែលគេសរសេរកាត់ដូចជា ស.រ.អា. (សហរដ្ឋអាមេរិក), អ.ស.ប. (អង្គការសហប្រជាជាតិ) គ.ជ.ប. (គណៈកម្មការជាតិរៀបចំការបោះឆ្នោត) ជួនកាលគេប្រើអាទិសង្កេត ដើម្បីដាក់ពីមុខលេខរៀង មាតិកាដែលរៀបរាប់ចំណងជើងរង (Sous-titre) ដូចជា ៖

១. មង្គលការ អបមង្គល
២. ស្វាស្អប់ចេក ក្អែកស្អប់ពងមាន់
៣. ចង់រត់ចេញពីសង្គម...

ជួនកាលក្នុងករណីដូចខាងលើនេះ គេប្រើរជ្ជុសញ្ញា (-) ខ្លះ ៗ ដែរ ។

## ១៥- កុក្កុដនេត្រ ឬ ភ្នែកមាន់ (៙)

បុព្វក វីនិពន្ធខ្មែរធ្លាប់ប្រើសញ្ញានេះ សម្រាប់ចាប់ផ្តើមសរសេរអត្ថបទ ឬសេចក្តីរឿងអ្វីមួយដើម្បីកំណត់ទុកជាចំណុចចាប់ផ្តើម ។ តែពេលបច្ចុប្បន្ននេះ អ្នកនិពន្ធ កវីលែងប្រើសញ្ញានេះហើយ ។ ជាពិសេសនៅពេលចាប់ផ្តើមសរសេរកំណាព្យ នោះកវីបុរាណយើងច្រើនប្រើសញ្ញា (៙) ដូច្នេះ ។ បច្ចុប្បន្ននេះ មានកវីសម័យទំនើបខ្លះក៏ផ្តើមប្រើសញ្ញាផ្នែកមាន់ ដែលមានក្បៀសពីរនេះ នៅពេលចាប់ផ្តើមបើកបទកំណាព្យ ។

## ១៦-ខណ្ឌបរិយោសាន ឬ គោមូត្រ (៚)

គឺ ជាសញ្ញាយកតាមរូបសណ្ឋានដាននោមគោ ដែលនោមផងដើរផង បណ្តាលឲ្យមានរាងក្ងិក្ងក់បែបនេះ ហើយខ្មែរបុរាណក៏សន្មតយកមកធ្វើជាសញ្ញាខណ្ឌបញ្ចប់ ដែលហៅតាមពាក្យបាលីថា «**គោមូត្រ**» គឺនោមគោដូច្នេះទៅ ។ ចាស់បុរាណលោកប្រើខណ្ឌបរិយោសាន ឬ បរិយាន ឬគោមូត្រនេះ សម្រាប់បញ្ជាក់សេចក្តីនិយាយពីរឿងរ៉ាវអ្វីមួយឬអត្ថបទ បទបាទបាលីគាថាណាមួយ ។ សព្វថ្ងៃនេះ អ្នកនិពន្ធមួយចំនួន បានប្រើសញ្ញាពីរគឺៈ ឬមួយ ៕ ឬមួយ ។៚ ។ ការប្រើគោមូត្រនេះ គឺចង់រក្សាសម្បត្តិវប្បធម៌ពីបុរាណឲ្យនៅគង់វង្ស ។ យើងឃើញអ្នកកាសែតមួយចំនួន មានប្រើសញ្ញាគោមូត្រផងដែរ ៕៚

## ១៧-អំពីលេខខ្មែរ

តាំង ពីយូរមកហើយ ខ្មែរយើងប្រើលេខ ព្រមជាមួយនឹងការបង្កើតតួអក្សរ សម្រាប់ចារឹក និង កត់ត្រាហេតុការណ៍ផ្សេងៗ ។ លេខមានសារៈសំខាន់ ជាពិសេសក្នុងការកត់ត្រាចំនួនលុយកាក់ គោក្របី ស្រែភ្លឺ ខ្ញុំកំដរ... ។ កត់ត្រា អាយុ (ចំនួនឆ្នាំ) ដែលខ្លួនរស់នៅកត់ត្រាចំនួនប្រាក់ដែលគេមកខ្ចីបុល... ។

នៅ ពេលបច្ចុប្បន្ន លេខត្រូវបានប្រើប្រាស់សម្រាប់គណនាលុយកាក់ថវិកាចំណូលចំណាយ ។ ពិសេសស្ថាប័នហិរញ្ញវត្ថុ, ស្ថាប័នសេដ្ឋកិច្ច, ធនាគារ, ពាណិជ្ជកម្ម ត្រូវការប្រើប្រាស់តួលេខជាចម្បងបំផុត ។ ព្រោះតែ «**លេខ**» មានតួនាទីសំខាន់នៅក្នុងសង្គមនេះហើយ ទើបមានពាក្យស្លោកមួយឃ្លាថែងថា៖“សម្តីជាឯក លេខជាទោ អក្សរជាត្រី ” តាំងពីសម័យដើមមកទល់ពេលនេះ ទម្រង់បែបផែនលេខដែលខ្មែរយើងប្រើប្រាស់មាន ៖

### ក/ លេខទំនើបដែលខ្មែរយើងប្រើសព្វថ្ងៃគឺ ៖

**0, ១, ២, ៣, ៤, ៥, ៦, ៧, ៨, ៩ ។**

### ខ/ លេខអារ៉ាប់ ៖

**0, 1, 2, 3, 4, 5, 6, 7, 8, 9 ។**

ស្ទើរតែនៅលើសកលលោក គេប្រើលេខនេះ ទុកដូចជាលេខអន្តរជាតិទៅហើយ ។

### គ/ លេខខ្មែរបុរាណ

លេខប្រភេទនេះ មានតែពួក «**ហោរា**» (Astrologue) ប៉ុណ្ណោះ ដែលប្រើក្នុងការទស្សន៍ទាយជោគតារាសីឲ្យមនុស្សទូទៅ និងទស្សន៍ទាយមើលសុខទុក្ខ, ព្រឹត្តិការណ៍, ទឹកភ្លៀង ឬកេណ្ឌធារាសាស្ត្រផលាផលប្រចាំឆ្នាំ សម្រាប់ចុះផ្សាយក្នុងមហាសង្ក្រាន្ត ។ គេរាប់លេខនេះថា ៖ **ឯក , ទោ, ត្រី, ចត្វា, បញ្ច, ឆ, ស័ប្ត, អដ្ឋ, នព, សំរិទ្ធិ** ។ សូមបង្ហាញជូននូវរូបសញ្ញានៃលេខខ្មែរបុរាណដូចខាងក្រោម ៖

**៰, ៱, ៲, ៳, ៴, ៵, ៶, ៷, ៸, ៹ ។**

### ឃ/លេខរ៉ូម៉ាំង (Chiffre romain)

លេខរ៉ូម៉ាំង ច្រើនសរសេរ ៖

1. នៅលើមុខនាឡិកាប៉ោលព្យួរជញ្ជាំង
2. សម្រាប់ កត់ត្រា ភាគ, ជំពូក, ផ្នែក, នៃអត្ថបទ ឯកសារសៀវភៅផ្សេងៗ ។ ខាងក្រោមនេះ គឺរូបសញ្ញាតួនៃលេខរ៉ូម៉ាំង I, II, III, IV, V, VI, VII, VIII, IX, X [17]។

នៅកម្ពុជាយើង គេប្រើទាំងអស់ លេខទាំងប៉ុន្មានដែលបានបង្ហាញជូនខាងលើ ។ លើកលែងតែអស់លោក «**ហោរា**» ទេ ដែលប្រើលេខខ្មែរបុរាណ ក្នុងការគណនាទស្សន៍ទាយ តាមលេខអត្ថ:ទស្សន៍ទាយ ជោគជតារាសី ។

## ១៨-ការចុះកាលបរិច្ឆេទ

ការ ចុះកាលបរិច្ឆេទមានតួនាទីសំខាន់ជាចម្បង ព្រោះតាមរយៈកាលបរិច្ឆេទ គេអាចដឹងអំពីកាលវេលា ដែលព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនានាបានកើតឡើង ។ ឧ. កាលបរិច្ឆេទនៃការឡើងសោយរាជ្យនៃស្ដេចអង្គណាមួយ, កាលបរិច្ឆេទនៃការកសាងប្រាសាទ... កាលបរិច្ឆេទនៃជ័យជម្នះរបស់ជាតិយើង ទៅលើគូសត្រូវ កាលបរិច្ឆេទនៃការចាកចោលក្រុងអង្គរ... កាលបរិច្ឆេទនៃការផ្លាស់ប្ដូររាជធានី ។ល។ នៅក្នុងគ្រួសារមួយ ការសាងសង់ផ្ទះថ្មី ក៏មានចារឹកកាលបរិច្ឆេទទុកជាសម្គាល់ សម្រាប់ឲ្យសមាជិកគ្រួសារជំនាន់ក្រោយៗបានដឹង។ នៅតាមចេតិយម៉ុងបញ្ចុះសព ក៏គ្រួសារនីមួយៗ តែងតែសរសេរឈ្មោះ បុគ្គលជាសាច់ញាតិដែលស្លាប់ ។

### ការចុះកាលបរិច្ឆេទតាមបែបបុរាណ

ចាប់ ពីរវាងសតវត្សទី១៦ រហូតមកទល់ដើមសម័យភ្នំពេញបុព្វបុរសយើងប្រើរបៀបម្យ៉ាង សម្រាប់ធ្វើជារូបមន្តនៃការចុះកាលបរិច្ឆេទ ។ គោលសំខាន់នៃរូបមន្តនោះ គឺលោកដាក់សញ្ញាខណ្ឌ (។) ទុកជាគោលសម្រាប់ធ្វើស្នូលកណ្តាល ។ យើងឃើញការចុះកាលបរិច្ឆេទរបៀបនេះនៅលើចេតិយ នៅលើសំណង់ផ្សេងៗ ខាងពុទ្ធសាសនា ជាពិសេស យើងឃើញនៅគ្រប់តែសន្លឹកខាងដើមបំផុត ឬសន្លឹកចុងបញ្ចប់នៃសាស្ត្រាស្លឹករឹត ។ ឧទាហរណ៍៖ ថ្ងៃអង្គារ ១១ កើត ពិសាខ ព.ស. ២៥៤៩ គ.ស. ២០០៥ នោះគេសរសេរបែបនេះវិញ ៖

**ព.ស. ២៥៤៩**
**៣ ១ៗ ៦ ឆ្នាំមមែ**
**គ.ស. ២០០៥**

នេះ គឺជារបៀបចុះកាលបរិច្ឆេទបែបសង្ខេបខ្លី ។ ខ្ញុំគ្រាន់តែសូមជម្រាបថា ដើម្បីចេះចុះកាលបរិច្ឆេទរបៀបបុរាណនេះ គេត្រូវចេះចាំថ្ងៃទាំង៧ ឲ្យស្ទាត់ គឺ អាទិត្យ (លេខ១) ច័ន្ទ (លេខ២) អង្គារ (លេខ៣) ពុធ (លេខ៤) ប្រហស្បតិ៍ (លេខ៥) សុក្រ (លេខ៦) សៅរ៍ (លេខ៧) ។ រួចហើយត្រូវចេះ រាប់ខែចន្ទគតិឲ្យស្ទាត់ ដោយដាក់លេខឲ្យខែនីមួយៗផងគឺ៖ មិគសិរ (លេខ១) បុស្ស (លេខ២) មាឃ (លេខ៣) ផល្គុន (លេខ៤) ចេត្រ (លេខ៥) ពិសាខ (លេខ៦) ជេស្ឋ (លេខ៧) អាសាឍ (លេខ៨) ស្រាពណ៍ (លេខ៩) ភទ្របទ (លេខ១០) អស្សុជ (លេខ១១) កត្តិក (លេខ១២) ។ ការគិត ខ្នើត រនោច គឺលោកកំណត់ឲ្យដាក់ខ្នើតនៅខាងលើសញ្ញាខណ្ឌ, ឲ្យដាក់រនោចនៅខាងក្រោមសញ្ញាខណ្ឌ ។ ឧទាហរណ៍ ៖ ថ្ងៃសៅរ៍ ៣ រោច ខែ អាសាឍ គ.ស. ២០០១ ព.ស. ២៥៤៨ ត្រូវសរសេរដូចខាងក្រោម ៖

**ព.ស. ២៥៤៨**
**៧ ៗ៣៨ ឆ្នាំឆ្លូវ**
**គ.ស. ២០០៤**

## ១៩-អំពីទម្រង់ផ្សេងៗនៃអក្សរខ្មែរ (Les différents types de caractères Khmers)

អក្សរខ្មែរ មានទ្រង់ទ្រាយច្រើនបែប, មានដូចជា ៖

**ក/ អក្សរជ្រៀង (Ecriture penchée)** ៖ អក្សរជ្រៀង គឺជាអក្សរដៃ (manuscrit) មានជំហររាងទ្រេតទៅមុខ ។

**ខ/ អក្សរត្រង់ (Eeriture droite)** ៖ គឺជាទម្រង់អក្សរ ដែលគេសរសេរ ឲ្យមានជំហរត្រង់ ទៅលើតាមទំនងបន្ទាត់បញ្ឈរ (vertical) ។

ប៉ុន្តែ គេកម្រឃើញទម្រង់អក្សរ សរសេរទ្រេតទៅខាងឆ្វេងណាស់ (ទ្រេតទៅក្រោយ) ។

**គ/ អក្សរមូល**[18]

**អក្សរមូល** គឺជាប្រភេទអក្សរ ដែលមានទម្រង់មូល ។ គេច្រើនសរសេរអក្សរមូល នៅក្នុងសៀវភៅធម៌ ជាភាសាបាលី ឬ សំស្ក្រឹត ។ ម្យ៉ាងទៀត ការសរសេរមន្តអាគមគាថា លើកន្សែងយ័ន្តលើអាវគេជះ សាក់លើខ្លួនប្រាណ, ក៏គេនិយមប្រើអក្សរមូលដែរ ។ នៅទូទាំងស្រុកសៀម (ថៃ) កាលណាគេសរសេរបាលីគាថា **មន្តអាគម** គឺគេសរសេរអក្សរមូលខ្មែរទាំងអស់ ។ គេនិយមយល់ថា កាលណាគេសរសេរអក្សរ (សៀម) នៅលើយ័ន្ត មន្តអាគមគាថា នោះមិនពូកែសក្តិសិទ្ធិ ដូចសរសេរអក្សរមូលខ្មែរទេ ។

**ករណីលើកលែង**

ប៉ុន្តែ ដោយឡែក ហើយនេះជាករណីពិសេស ដែលជាទម្លាប់របស់ខ្មែរយើងស្រាប់ផង នៅលើស្លាក (Enseigne) ឃីហោផ្ទះជំនួញ ស្លាករបស់មន្ទីរក្រសួងនានា ឈ្មោះចំណងជើងសៀវភៅ ឈ្មោះអ្នកនិពន្ធ... នោះគេច្រើនតែសរសេរអក្សរមូលផងដែរ ។ ឧទាហរណ៍ ៖ រោងចក្រម៉ុងហ្សួត, ក្រសួងឧស្សាហាកម្ម រ៉ែ និង ថាមពល, វចនានុក្រមបារាំង-ខ្មែរ ដោយលោក តិប យក់, ថាវ-គន្ធ សម ថាំង... ។ល។

**ឃ/ អក្សរខម**[19]

**អក្សរខម**នេះ មានទម្រង់ទ្រង់ទ្រាយមូល ប្រហាក់ប្រហែលនឹងអក្សរមូលដែរ ប៉ុន្តែមានចំណុចប្លែកគ្នាខ្លះៗ ដូចជា ៖

1. អក្សរ «**ក**» មានពីរជាន់ ជើងបីបែបនេះ «**ក**» ។
2. គ្រប់តួអក្សរ ច្រើនតែមានងៀងជ្រុងបន្តិច នៅត្រង់ចុងមុម ។
3. អក្សរ «**ម**» មានបន្ទាត់ វះពោះភ្ជាប់ពីម្ខាងដល់ម្ខាង «**ម**» [20] ។
4. ស្រៈ «**ែ**» មានទម្រង់បែបនេះ «**ែ**» [21]

គេ ប្រើសរសេរអក្សរ ខម ប្រហាក់ប្រហែលគ្នានឹងអក្សរមូលដែរ តែមិនសរសេរក្នុងយ័ន្ត គាថាទេ ។ គេច្រើនសសេរចុះចំណងជើងសៀវភៅ , ចំណងជើងអត្ថបទ , ឈ្មោះជំពូក, វគ្គ, ផ្នែកនៃសៀវភៅមួយ ។ ដោយចង់ថែរក្សាទម្រង់អក្សរ បន្សល់ទុកមកដោយបុព្វបុរសខ្មែរ គេចម្លងគំរូអក្សរខមនេះ ពីសិលាចារឹក ក្រោយអង្គរខ្លះ ពីសាស្ត្រាស្លឹករឹតខ្លះ រក្សាទុកជាគេរមតិកខាងអក្សរសាស្ត្រ កុំឲ្យបាត់បង់ ។

## ២០-ការប្រើឈ្មោះខែតាមបែបបារាំង

តាំង ពីប្រទេសយើងឋិតនៅក្រោមរដ្ឋការអាណាព្យាបាលបារាំងមក ក្រៅពីប្រើកាលបរិច្ឆេទតាមបែបចន្ទគតិ ខ្មែរយើងប្រើកាលបរិច្ឆេទបែបសុរិយគតិតាមបារាំង ព្រោះរដ្ឋការរបស់បារាំងនិងខ្មែរយើង មានការប្រាស្រ័យទាក់ទងគ្នាជាប្រចាំ ។ ម្យ៉ាងទៀតឥទ្ធិពលបារាំង ទាំងនយោបាយ និងវប្បធម៌ តែងតែគ្របសង្កត់មកលើយើងជានិច្ច ។ សូមជម្រាបបញ្ជាក់ថា បារាំងពុំមានប្រើឈ្មោះឆ្នាំ ជូត, ឆ្លូវ, ខាល, ថោះ, រោង.... ដូចយើងទេ គឺគេប្រើឆ្នាំតាមគ្រិស្តសករាជ ។

ឧទាហរណ៍៖ គ្រិស្តសករាជ ២០០៧ ។ ក្រៅពីប្រើឆ្នាំតាមគ្រិស្តសករាជ បារាំងប្រើខែសុរិយគតិដូចជា Janvier (ហ្សង់វីយេ), Février (ហ្វេវ្រីយេ), Mars (ម៉ាស់), Avril (អាវ្រីល), Mai (ម៉េ), Juin (យ្ហូវ៉ាំង), Juillet (ស៊្វីយ៉េត), Août (អ៊្វូត), Septembre (សេបតមប្រ៍), Octobre (អុកតូប្រ៍), Novembre (ណូវ៉ែមប្រ៍) និង Décembre (ដេសមប្រ៍) ។

ក្រោយ មក ក្នុងរវាងបណ្តាឆ្នាំ ទសវត្សទី៦០ គណៈកម្មការវប្បធម៌ជាតិ បានបង្កើតឈ្មោះ ខែសុរិយគតិទាំង១២ ជាភាសាបាលីជំនួសខែសុរិយគតិបារាំង ដូចខាងក្រោមនេះ៖

១- Janvier = យ៉ាំងវីយេ = មករា ២- Février = ហ្វេវ្រីយេ = កុម្ភៈ ៣- Mars = ម៉ារ្ស = មីនា ៤-Avril =អាវ្រីល= មេសា ៥- Mai = ម៉េ = ឧសភា៦- Juin = យូវ៉ាំង = មិថុនា ៧- Juillet = ស៊្វីយេត= កក្កដា ៨- Août = អ៊្វូត = សីហា ៩- Septembre =សេបតមប្រ៍=កញ្ញា ១០- Octobre = ឧកតូប្រ៍= តុលា ១១- Novembre=ណូវ៉ែមប្រ៍=វិច្ឆិកា ១២- Décembre= ដេសមប្រ៍ =ធ្នូ ។

នេះ ជាដំណាក់កាលនៃការវិវត្តន៍របស់ភាសា និងអក្សរសាស្ត្រខ្មែរយើង ក្នុងជំហានថ្មីមួយទៀត ។ ប៉ុន្តែ សូមជម្រាបថា ឈ្មោះខែថ្មីរបស់ខ្មែរយើង ដែលយកមកជំនួសខែសុរិយគតិបារាំង(ឬសកល) នេះពុំអាចយកទៅប្រើប្រាស់ក្នុងផ្នែកហោរាសាស្ត្រសម្រាប់ទស្សន៍ទាយ

ជោគជតារាសី គ្រោះកាច គ្រោះជា... បាននោះឡើយ ។ ហោរាខ្មែរនៅតែប្រើខែខាងចន្ទគតិសម្រាប់គន់គូរដដែលដូចជា ៖

-មិគសិរ= លេខ ១ -ជេស្ឋ = លេខ ៧
-បុស្ស = លេខ ២ -អាសាឍ = លេខ ៨
-មាឃ= លេខ ៣ -ស្រាពណ៍= លេខ ៩
-ផល្គុន = លេខ ៤ -ភទ្របទ = លេខ ១០
-ចេត្រ = លេខ ៥ -អស្សុជ = លេខ ១១
-ពិសាខ = លេខ ៦ -កត្តិក = លេខ ១២

## ពាក្យអញ្ញត្រស័ព្ទ

**(Les mots exceptionnels)**

គឺជាពាក្យមានលក្ខណៈពិសេស ខុសប្លែកពីពាក្យឯទៀតៗដោយ អក្ខរាវិរុទ្ធមិនចំណុះនិងសូរសំឡេង។

ឧទាហរណ៍

- អ្នក= អានថា = «នាក់» សរសេរជា អ + ្ន + ក=អនក=អ្នក=នាក់ ។
- អញ=អានថា = «អាញ់» សរសេរជា =អញ ។
- (ខាង)លិច(ទិស) អានថា= «ឡិច» សរសេរជា =លិច ទិសដែលព្រះអាទិត្យលិច ។
- មាតា=អានថា = «មាដា» សរសេរជា =មាតា= ត> ដ; បាលីមាតា(មា+តា) អានជាសំឡេងខ្មែរ=ម៉ែ ។
- មណ្ឌប. ន. អានថា «មាន់ដប់» = វិមាន, រោង ។
- ភ្នំព្រះសុមេរុ = អានថា «ព្រះសុម៉ែ» ភ្នំខ្ពស់ជាងគេក្នុងលោក ។
- ខេត្ត = អានថា «ខែត» មកពីបាលី ខេត្ត=ស្រែ ។
- វិសេស= អានថា «វិសែស» មកពីបាលី វិសេស= ភាពប្លែក ។
- សេពគប់= អានថា «សែបគប់» ទាក់ទងរាប់រក; បាលីក្លាយខ្មែរ ។
- តេមិយៈ= អាថា «ឌីម៉ែ ឬ ព្រះឌីម៉ែ» រឿងទី១ ក្នុងទសជាតក; ... ។
- តេជោ= អានថា «ដេជោ» មកពីបាលី «តេជ»= អំណាច ។
- បណ្ឌិត=ហៅក្លាយជា «អន្ទិត» មកពីពាក្យបាលី=ជនអ្នកមានប្រាជ្ញា ។

- បេតី= អានថា «ប៉ៃតី», ក្លាយមកពី «បីតិ» ។
- ចេតិយ= អានថា «ចៃដី» មកពីពាក្យបាលី=ទីដែលគេគោរពបូជា ។
- ចេស្តា= អានថា «ចៃស្តា» មកពីសំស្ក្រឹត=សង្វាតប្រឹងប្រែង ។
- ចេតនា= អានថា «ចៃតាណា» មកពីបាលី= ផ្ដូចគិត, ផ្ដោតចិត្ត ។
- ព្រះធរណី= អានថា «ព្រះធរនី» មកពីបាលី,សំស្ក្រឹត= ផែនដី[22] ។
- ប្រពៃណី= អានថា «ប្រពៃនី[23]» មកពីបាលី= ទំនៀម, ពូជពង្ស ។
- អនុលោម= អានថា «អនុឡោម» មកពីបាលី= បណ្ដោយតាម, យល់តាម ។

ខ្ញុំស្រង់ពាក្យ «**អញ្ញត្រស័ព្ទ**» ខ្លះៗប៉ុណ្ណោះ យកបង្ហាញជូនអស់លោក គ្រាន់បានជាគំរូប៉ុណ្ណោះ ។ នៅមានពាក្យប្រភេទនេះច្រើនទៀត ។ សូមអស់លោកជួយស្រាវជ្រាវបន្ថែម តាមការគួរ ។

**សង្កេត** ៖ ក្នុងចំណោមអញ្ញត្រស័ព្ទទាំងអស់នេះ យើងសង្កេត ឃើញមានលក្ខណៈពិសេស៥យ៉ាងគឺ ៖

1. ពាក្យទាំងនេះ ច្រើនតែក្លាយមកពីពាក្យបាលី និងសំស្ក្រឹត ។
2. យកសំឡេង «**ដ**» មកជំនួស សំឡេង «**ត**» ; ឧ. បីដា ‹ បិតា ។
3. យកស្រៈ «**ៃ**» មកជំនួសស្រៈ «**េ**» ឧ. ចៃដី ‹ ចេតិយ ។
4. យកព្យញ្ជនៈសំឡេង «**អ៊**» មកជំនួសព្យញ្ជនៈសំឡេង «**អ**» ; ឧ. ព្រះធរនី ‹ ព្រះធរណី, ប្រពៃនី ‹ ប្រពៃណី ។
5. យក្យព្យញ្ជនៈសំឡេង «**អ**» មកជំនួសព្យញ្ជនៈសំឡេង «**អ៊**» ឧ.ទិសខាងឡិច ...។ បាតុភូតអញ្ញត្រស័ព្ទ គឺជា «សោភ័ណភាសា» ដែលទាំងអ្នកអក្សរសាស្ត្រ ទាំងមហាជនព្រមព្រៀងគ្នាប្រឌិតឡើង សម្រាប់សម្រួលការនិយាយស្ដី ឲ្យស្រួលមាត់ ។ រីឯការសរសេរវិញ ត្រូវតែគោរពអក្ខរាវិរុទ្ធដោយអនុលោមទៅតាមជាតិសព្ទ(Etymologie) របស់ពាក្យ ។

## ២១- អក្សរកាត់

នៅ ក្នុងការសរសេរអត្ថបទផ្សេងៗ ជួនកាលគេសរសេរពាក្យនៅក្នុងឃ្លាណាមួយដោយប្រើពាក្យពេញលេញទាំង ស្រុងតែម្ដង ។ ឧ. អង្គការសុខភាពពិភពលោក (O.M.S.) ។

ជូន កាលក្នុងកាលៈទេសៈខ្លះទៀត ដោយគេចង់ចំណេញពេល ចំណេញក្រដាស គេតែងតែរិះរកវិធីបំព្រួញសង្ខេបពាក្យពេញលេញនោះឲ្យខ្លី ប៉ុន្តែនៅតែរក្សាបានអត្ថន័យខ្លឹមសារវាទាំងស្រុងដដែល ។

ឧ. អង្គការសហប្រជាជាតិ រួមមកនៅត្រឹម អ. ស. ប.
សហរដ្ឋអាមេរិក ស. រ. អា.
គណកម្មាធិការជាតិភាសាខ្មែរ គ. ជ. ភ. ខ.
សេចក្តីជូនដំណឹង ស. ជ. ណ.

**វិធី៖** គេ ជ្រើសយកព្យញ្ជនៈក្នុងពាក្យណាមួយធ្វើជាគោល ។ ពាក្យគោលនៅក្នុងឃ្លាណាមួយនោះ ត្រូវបានកំណត់ជ្រើសរើសយកមកដាក់តម្រៀបជាបន្តបន្ទាប់រហូតដល់អស់ ពាក្យគោលដូចមានបញ្ជាក់ជូននៅក្នុងឧទាហរណ៍ខាងលើស្រាប់ ។

## ២២- ឋានៈរបស់ពាក្យ

### ក/ ចំពោះព្រះសង្ឃ និងព្រះរាជា

ដើម្បីរាប់កំណត់ចំនួនព្រះរាជានោះ គេប្រើពាក្យភ្ជាប់ថា «**អង្គ**» ៖ ឧ. ព្រះមហាក្សត្រា ក្សត្រីយាងចូលប្រថាប់ក្នុងរាជរោងមាន ១៧ អង្គ ។

ដើម្បីកំណត់ចំនួនព្រះសង្ឃ គេប្រើពាក្យភ្ជាប់ថា «**អង្គ**» ៖ ឧ.ក្នុងពិធីចម្រើនព្រះបរិត្តបុណ្យទក្ខិណានុប្បទាននេះ គេនិមន្តព្រះសង្ឃ ១០ “អង្គ” ។

**បញ្ជាក់** ៖ ពាក្យ សង្ឃស័ព្ទ និងរាជស័ព្ទ មួយចំនួន គឺជាន់គ្នាតែមួយប្រើពាក្យដូចគ្នា ដូចករណីខាងលើជាភស្តុតាងស្រាប់ ។ ព្រះរាជាឈឺ និងព្រះសង្ឃឈឺ គេអាចហៅថា «**អាពាធ**» ដូចគ្នាបាន តែចំពោះព្រះរាជា មានពាក្យម្យ៉ាងទៀតថា «**ប្រឈួន**» ។

ខ្មែរ យើងប្រើពាក្យពិសេសៗ សម្រាប់តម្រូវនឹងឋានៈមនុស្សក្នុងសង្គម ។ ដូច្នេះ ព្រះសង្ឃ និងព្រះរាជា ជាជនមានឋានៈខ្ពស់ក្នុងសង្គម ដែលគេអាចសន្មតថា ជា «**ឧត្តមភេទ**» ដូច្នេះត្រូវតែមានពាក្យខ្ពង់ខ្ពស់យកមកប្រើ ឲ្យត្រូវទៅតាមឋានៈនាទី ក្នុងសង្គមដូចជម្រាបខាងលើ ។

### ខ/ ចំពោះមនុស្សដែលមានឋានន្តរសក្តិខ្ពង់ខ្ពស់

ដើម្បីកំណត់ចំនួនមនុស្សមានយសសក្តិខ្ពង់ខ្ពស់វិញ គេប្រើពាក្យ «**រូប**» ៖ ឧ. នៅក្នុងពិធីសម្ពោធការដ្ឋាន នៅខេត្តកំពង់ចាម មានអស់លោករដ្ឋមន្ត្រី តំណាងរាស្ត្រ ចូលរួមប្រមាណ ៣០ រូប ។

## គ/ ចំពោះមនុស្សសាមញ្ញធម្មតា

ក្នុងការរាប់កំណត់ចំនួនមនុស្សសាមញ្ញធម្មតា គេភ្ជាប់ពាក្យ «**នាក់**» ៖ ឧ. នៅក្នុងពិធីបុណ្យ សុំទឹកភ្លៀងនៅទីទួលអ្នកតាដើមពោធិ៍ មានមនុស្សប្រុសស្រី ក្មេងចាស់ចំនួនប្រមាណជាង៥០០ នាក់ ចូលរួម ។

## ឃ/ ចំពោះសត្វទូទៅ

ក្នុងការគិតគន់គណនាចំនួនសត្វទូទៅ គេតែងប្រើពាក្យ «**ក្បាល**» ៖ ឧ. គេពិឃាតគោ និងជ្រូក អស់ចំនួន ៤ ក្បាល ។ តែដោយឡែក, បើចំពោះសៀវភៅវិញ ក៏គេហៅថា «**ក្បាល**» សៀវភៅ ១០ ក្បាល (ដែរ) ។

## ង/ ចំពោះវត្ថុផ្សេងៗ

- ផ្ទះ គេប្រើពាក្យ «**ខ្នង**» យកមកភ្ជាប់ពីក្រោយ ឧ. ផ្ទះ ៣ ខ្នង ។
- អិដ្ឋ គេប្រើពាក្យ «**ដុំ**» យកមកភ្ជាប់ពីក្រោយ ឧ. អិដ្ឋ ២០០ ដុំ ។
- ក្បឿង គេប្រើពាក្យ «**សន្លឹក**» យកមកភ្ជាប់ពីក្រោយ ឧ.ក្បឿង ៥០០០ សន្លឹក ។
- ស័ង្កសី គេប្រើពាក្យ «**សន្លឹក**» យកមកភ្ជាប់ពីក្រោយ ឧ. ស័ង្កសី ៧០ សន្លឹក ។
- ក្ដារ គេប្រើពាក្យ «**សន្លឹក**» យកមកភ្ជាប់ពីក្រោយ ឧ. ក្ដារ ១៨០ សន្លឹក ។
- ក្រដាស គេប្រើពាក្យ «**សន្លឹក**» យកមកភ្ជាប់ពីក្រោយ ឧ. ក្រដាស ១០០០ សន្លឹក ។
- គ្រឿងឈើធ្វើសំណង់ គេប្រើពាក្យ «**ផ្លាន**» យកមកភ្ជាប់ពីក្រោយ រនូត, រត, ប្រម៉េ, ផ្ទោង ៤០ ផ្លាន ។
- រថយន្ត, កប៉ាល់,ទូក គេប្រើពាក្យ «**គ្រឿង**» យកមកភ្ជាប់ពីក្រោយ ឧ. រថយន្ត ៣ គ្រឿង ។ ឧ. កប៉ាល់ ២ គ្រឿង ។ ឧ. ទូក ៥ គ្រឿង ។

## ច/ ចំពោះរុក្ខជាតិ

ដំណាំដើមឈើធំៗ គេប្រើពាក្យ «**ដើម**» យកមកភ្ជាប់ពីក្រោយ ៖ ឧ. ខ្នុរ ៣០ ដើម ដូង ៥០ ដើម ។

## ឆ/ ចំពោះសត្វទូទៅ

ដើម្បីរាប់កំណត់ចំនួនសត្វសម្រាប់ទឹម, គេតែងយកពាក្យ «**នឹម**» មកភ្ជាប់ពីក្រោយ ។

## ជ/ ចំពោះដំណាំវារ, ទ្រើងតូចតាច

ដើម្បីគណនាចំនួនដំណាំប្រភេទនេះ គេប្រើពាក្យ «**គុម្ព**» មកភ្ជាប់ពីក្រោយ ៖ ឧ. កសិករគំរូនៅភូមិសំរោង បានដាំដំណាំបន្លែជាច្រើន សម្រាប់លក់ និងសម្រាប់បរិភោគក្នុងគ្រួសារដូចជា ៖

- ត្រឡាច ២០ គុម្ព ។
- ស្ពៃខ្មៅ ១០០ គុម្ព ។
- ខាត់ណា ៥០ គុម្ព ។

## ឈ/ ចំពោះដំណាំយកស្លឹក, ផ្លែ, ជាវល្លិ៍

ក្នុង ការគណនារាប់ដំណាំប្រភេទនេះ គេប្រើពាក្យ «ជន្លង់» ពីខាងក្រោយ ៖ ឧ. ពូឡាយ ហាក់ដែលមានចម្ការប្រភេទដីក្រហម, គាត់ដាំម្រេច៥០០ ជន្លង់ ដីមួយងារនៅខាងក្រោយផ្ទះ, គាត់ដាំ ម្លូក្រហម ២០ ជន្លង់ ។

## ញ/ ចំពោះសម្លៀកបំពាក់ ឬវត្ថុផ្សេងៗទៀត

បើរាប់ខោមួយ អាវមួយ ឬសំពត់មួយ អាវមួយ, គេថា «**ប្រដាប់**» ៖

- គឺខោអាវ, សំពត់អាវ ១ ប្រដាប់ ។
- ឬខោអាវ ១ កុំប្លេ ។
- បើរាប់ ឬគណនាសំពត់ គេប្រើពាក្យ «**ក្បិន**» គឺ សំពត់ ១ ក្បិន ។
- បើរាប់កំណត់ទំហំល្មម កាត់ខោអាវបានគេថា «**អាវ**» ឧ. កំណាត់ ១ អាវ ។
- បើរាប់គណនាស្បែកជើង, គេប្រើពាក្យ «**សម្រាប់**» ឧ. ស្បែកជើង ១ សម្រាប់ ។
- បើរាប់គណនាសង្រែក, គេប្រើពាក្យ «**សម្រាប់**» ឧ. សង្រែក ១ សម្រាប់ ។
- បើរាប់គណនាចង្កឹះ, គេប្រើពាក្យ «**គូ**» ឧ. ចង្កឹះ ១ គូ ។

- បើរាប់ ឬគណនាខ្សែវិញ គេភ្ជាប់ពាក្យ «**កន្ទុយ**» ពីខាងក្រោយ ឧ. ខ្សែគោ ១ កន្ទុយ ។
- បើរាប់ ឬគណនាចានវិញ គេភ្ជាប់ពាក្យ «**ស្រាក់ ឬឡូ**» ពីខាងក្រោយ ៖ ឧ. ចាន ១ ស្រាក់ ឬ ចាន ១ ឡូ ។

## ដ/ ចំពោះផ្លែឈើ

បើរាប់ ឬគណនាផ្លែឈើ, គេភ្ជាប់ពាក្យ ជាច្រើនប្រភេទដូចខាងក្រោម ៖

- បើផ្លែឈើ ៤ គេថា ផ្លែឈើ «**១ ដំប**» ។
- បើផ្លែឈើ ៤០ គេថា ផ្លែឈើ «**១ ផ្លូន**» ។
- បើផ្លែឈើ ៤០០ គេថា ផ្លែឈើ «**១ ស្លឹក**» ។
- របៀបរាប់សំណាប ដែលដកចងជាកណ្ដាប់បម្រុងយកទៅស្ទូង ក៏គេគិតជា «**ដំប**», «**ផ្លូន**», «**ស្លឹក**», ដូចផ្លែឈើដែរ ។
- បើរាប់ផ្លែស្លា គេគិតជា «**ដៃ**» ក្នុង ១ ដៃមាន ១០ ផ្លែ (ស្លា) ។
- បើរាប់ម្លូ គេគិតជា «**ស្ទើ**» ក្នុង១ស្ទើ មាន ១០ សន្លឹក (ម្លូ) ឬគេគិតជា «**ត្របក**» ក្នុង ១ ត្របកមាន ២០ សន្លឹក (ម្លូ) ។
- បើរាប់ដូង គេគិតជា «**ធ្លាយ**» គឺចង្កោមផ្លែដូងដែលចេញពី ទងមួយ ។
- បើរាប់ស្លា គេគិតជា «**ស្នែង**» គឺចង្កោមផ្លែស្លាដែលចេញពីទងមួយ ៖ ឧ. ដូង ១ ធ្លាយ, ស្លា ១ ស្នែង ។
- បើរាប់សម្លៀកបំពាក់ ដែលគេវេច គេហៅថា ១ ឬ ២ បង្វេច ។
- បើរាប់សម្លៀកបំពាក់ ដែលគេវេចល្មមស្ពាយបាន គេហៅថា ១ ឬ ២ សម្ពាយ ។
- បើរបស់អ្វីដែលគេយកមកឆ្វាយបានគេហៅថាខ្សែមួយចង្វាយ ។
- បើរបស់អ្វីដែលគេយកមកយួរបាន គេហៅថា មួយយួរ ។

## ឋ/ ការវាស់ពេលវេលាតាមបែបបុរាណ

កាល ដើមឡើយ ខ្មែរយើងពុំទាន់មានវិធី ឬឧបករណ៍សម្រាប់វាស់ពេល (លម្អិតខ្លី) ដូចគ្រាបច្ចុប្បន្នឡើយ ។ ហេតុនេះ ចាស់បុរាណ លោកកំណត់ពេលវែងខ្លីតាមរយៈការបង្កើតពាក្យផ្សេងៗ ហើយពាក្យខ្លះ នៅតែប្រើរហូតមកទល់សព្វថ្ងៃ មានដូចជា ៖

- **យាម**៖ ក្នុង ២៤ ម៉ោង លោកចែកជា ៦ ឬ ៨ យាម ក្នុងមួយយាមៗ មានប្រមាណពី ៣ ម៉ោង ទៅ ៤ ម៉ោង ។ គេគិតរាប់យាម១ ចាប់ពីថ្ងៃរះ គិតជាយាម៣ ឬយាម ៤ នៅពេល

ថ្ងៃលិច ។ ក្នុង ១ យប់ គិតជា ៤ យាម គឺពីព្រលប់គិតជាយាម ៤... ដល់ភ្លឺ គិតជាយាម ៨ ។

- **ខួប**៖ ការគិតអាយុក្មេង គេរាប់ពីខែ ដែលវាកើត រហូតមួយជុំ ដល់ថ្ងៃដដែលនេះវិញ គេហៅថាមួយខួបគឺត្រូវជា ១២ ខែ ។ ឧ. បើក្មេងកើតនៅ ថ្ងៃ ២ កើត ខែមាឃ..... លុះដល់វិលមួយជុំខួបមកដល់ថ្ងៃ ២ កើត ខែ មាឃ នេះ គេសន្មតថា ក្មេងនេះ អាយុបាន ១ ខួបហើយ ។ ការរាប់ឆ្នាំកំណើត ខ្មែរយើងមិនគិតតាមពុទ្ធសករាជឬគ្រិស្តសករាជទេ គឺកំណត់តាមឆ្នាំទាំង ១២ គឺ ឆ្នាំជូត, ឆ្លូវ, ខាល, ថោះ, រោង, ម្សាញ់, មមី, មមែ, វក, រកា, ច, កុរ ។ ក្នុង ១ ជុំ ខួបមាន ១២ ឆ្នាំ ... ។
- **មួយសន្ទុះ**៖ គឺជារយៈពេលជាកំណត់មួយ អាចស្មានបានប្រហែលជា ១ ម៉ោង ។ ឧ. ដើរបានមួយសន្ទុះ ក៏ចូលដល់ព្រៃធំមួយ.... ។
- **មួយបោក**៖ គឺជារយៈពេលជាកំណត់មួយ ប្រមាណជាកន្លះម៉ោង ។ ឧ. ដេកបានមួយបោក ភ្ញាក់ឡើងភ្លឺល្មម ។
- **មួយបារី**៖ គឺជារយៈពេលប្រមាណ ១៥ នាទី ។ ឧ. ច្រកថ្នាំចំនួនពេល ១ បារី អ្នកជំងឺក៏ដឹងខ្លួនវិញ ។
- **មួយសាបស្លា**៖ រយៈពេលប្រហែល ២០ នាទី ។ ឧ. ចម្ងាយផ្លូវពីភូមិ ធ្លកទ្រេតទៅ ឈើទាលជ្រំ គេត្រូវដើរ តែ១ សាបស្លា ប៉ុណ្ណោះ នឹងបានទៅដល់ហើយ ។
- **ចំណាំ**៖ ពេល ១ បារី គឺរយៈពេល ដែលគេជក់ថ្នាំអស់ ១ បារី ឯពេល ១ សាបស្លា គឺរយៈពេលដែលអ្នកស៊ីស្លា កំណត់ថាស្លាសាបអស់រសជាតិ ត្រូវខ្ជាក់ចោលកាកស្លាហើយ ។
- **មួយស្រទ្បេត**៖ គឺរយៈពេលខ្លី ប្រមាណ ៥ ទៅ ១០ នាទី ។ ឧ. ធ្មេចមួយស្រទ្បេតទៅ ក៏យល់សប្តិឃើញដំរីដេញ... ។
- **មួយភ្លែត**៖ ស្មើនឹងរយៈពេល ៥ នាទី ។ ឧ. កុំតាមម៉ែអី ម៉ែទៅតែមួយភ្លែតនឹងវិលមកវិញហើយ ។

# ឯកសារពិគ្រោះ


1. មូលវិជ្ជាខេមរភាសា ។
2. វេយ្យាករណ៍ ធន់ ហ៊ិន ។

3. ភាសាខ្មែរថ្នាក់ទី ១០ ក្រសួងអប់រំ ។
4. វេយ្យាករណ៍ខ្មែរពិស្តារ ពូវ - អ៊ុម ។
5. មូលភាពនៃការបង្កើតពាក្យ កេងវ៉ាន់សាក់ ។
6. វេយ្យាករណ៍ខ្មែរ យឹន សុខ ។
7. វេយ្យាករណ៍ខ្មែរ ក្រសួងអប់រំ ។
8. វេយ្យាករណ៍ ទម្រង់និយមនៃភាសាខ្មែរទំនើប ព្រុំ ម៉ល់ ។
9. ការតែងនិពន្ធ ជួរ គារី ។
10. និពន្ធសេចក្ដីខ្មែរ វិជ្ជានិពន្ធ គិត ហ៊ាង ។
11. ផ្កាស្រពោន នូ ហាច ។
12. កុលាបប៉ៃលិន ញ៉ុក ថែម ។
13. វេស្សន្តរជាតក ព្រះអង្គដួង ។
14. រឿងរតនាវង្ស ។
15. អក្សរសិល្ប៍ខ្មែរ លី ធាមតេង ។
16. ជិនវង្ស អរិយគាមុនី ហ៊ីង ។
17. កាកី ព្រះអង្គដួង ។
18. វេស្សន្តរជាតក ។

[1] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្នែល ឬទ្ធី អង់តែល្ម** ៖ មានស្រៈ ៥ ទៀត ពោលគឺ ាៈ (ឧ. ចាំៈ, អាៈ) ីៈ (ឧ. យីៈ !) ឺៈ (ឧ. អឺៈ, អ៊ឺៈ, វ៉ឺៈ, បឺៈ ៗ ! ទឺៈ ៗ !) ៀៈ (ឧ. វៀៈវៀន) និង េៈ (ឧ. ចេៈ) ។

-> ចំពោះស្រៈ ួ ឿ និង ៀ ជាមួយនឹងព្យញ្ជនៈអឃោសៈនិងឃោសៈ ខ្មែរយើងបញ្ចេញសំឡេងដូចគ្នាមែន តែជនជាតិខ្មែរនៅខេត្តចន្ទបុរី (សព្វថ្ងៃនៅប្រទេសសៀម) និងនៅតំបន់ភ្នំក្រវាញ កាលណាថា កួរ និង គួរ, កឿ និង គឿ, ហើយនិង កៀ និង គៀ នៅតែបញ្ចេញសំឡេងមិនដូចគ្នាទេ ពីព្រោះជាមួយនឹងព្យញ្ជនៈអឃោសៈ បញ្ចេញសំឡេងស្រាល (ឬហៅ សំឡេងតូច) ហើយជាមួយព្យញ្ជនៈឃោសៈ បញ្ចេញសំឡេងធ្ងន់ (ឬសំឡេងធំ) ។

[2] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្នែល ឬទ្ធី អង់តែល្ម** ៖ ពាក្យ សន្តោស, សន្តាន, ចិន្តា និង អន្តរធាន ត្រូវសរសេរនឹង ន្ត ដើម្បីរក្សាជាតិសព្ទ ព្រោះជាពាក្យមកពីសំស្ក្រឹត-បាលី ។ ពីដើម

ខ្មែរយើងធ្លាប់មានជើង «ដ» មានរូបសណ្ឋានដូចខ្លួនអក្សរ ដ តែបាត់សក់ សម្រាប់តែពាក្យសំស្ក្រឹត-បាលី ។ ជើងនេះ ខ្ញុំបាទប្រទះឃើញក្នុងសិលាចារឹកនគរវត្តសម័យក្រោយអង្គរ ឧទាហរណ៍ ក្នុងសិលាចារឹកលេខ ១ និង ៣ (សូមមើល សិលាចារឹកនគរវត្ត និង បទានុក្រម រៀបរៀងដោយមហាពិទូរក្រសេម ភ្នំពេញ ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី ២ គ.ស. ១៩៥៨ ព.ស. ២៥០១ ទំព័រទី ១២៦, ១៩០, ១៩១) និងក្នុងទស្សនាវដ្ដី កម្ពុជសុរិយា លេខដំបូងៗ លោកបានសរសេរពាក្យ «ទស្សនាវដ្ដី» នឹងជើង ដ ពុំមែនជាជើង ត ទេ ។

[3] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្នៃល ឫទ្ធី អង់តែល្ម** ៖ សរសេរ ត្រីស័ព្ទ ខ្ញុំបាទយល់ស្របជាមួយលោក តែក្នុងវចនានុក្រមខ្មែរ សរសេរថា ត្រីសព្ទ វិញ ។ តែត្រង់មេពាក្យ សព្ទ សរសេរថា សព្ទ ឬ ស័ព្ទ ។ ខ្ញុំបាទមិនដឹងជាអក្ខរាវិរុទ្ធណាត្រូវជាង ។

[4] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្នៃល ឫទ្ធី អង់តែល្ម** ៖ ស្រៈ ៚ ក្នុងភាសាបារាំងសែស ច្រើនអានថា ◌េ មិនមែនជា ◌ី ។ ក្នុង វចនានុក្រមខ្មែរ របស់ពុទ្ធសាសនបណ្ឌិត្យ លោកបានសរសេរឈ្មោះនេះថា ហ្សែក សេដែស ។

[5] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្នៃល ឫទ្ធី អង់តែល្ម** ៖ សរសេរ ត្រីស័ព្ទ ខ្ញុំបាទយល់ស្របជាមួយលោក តែក្នុងវចនានុក្រមខ្មែរ សរសេរថា ត្រីសព្ទ វិញ ។ តែត្រង់មេពាក្យ សព្ទ សរសេរថា សព្ទ ឬ ស័ព្ទ ។ ខ្ញុំបាទមិនដឹងជាអក្ខរាវិរុទ្ធណាត្រូវជាង ។

[6] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្នៃល ឫទ្ធី អង់តែល្ម** ៖ «អាសយ» ជាពាក្យបាលី ក្លាយជា «អាស័យ» តាមអក្ខរាវិរុទ្ធខ្មែរ ។ រីឯ «អាស្រ័យ» វិញ ជាពាក្យក្លាយមកពីសំស្ក្រឹត «អាឝ្រយ» (និងតួ ឝ ដែលខ្មែរយើងហៅថា ស-គ) ។

[7] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្នៃល ឫទ្ធី អង់តែល្ម** ៖ ◌័រ ក្នុងភាសាខ្មែរមាត្រដ្ឋាន (ភាសាខ្មែរស្តង់ដារ) មានតែជាមួយនឹងព្យញ្ជនៈឃោសៈ ដូចលោកបានសរសេរ ។ តែខ្ញុំបាទឃើញថា សព្វថ្ងៃនេះ (តាមពិត គឺតាំងពីទសវត្សរ៍ឆ្នាំ ១៩៦០) គេច្រើនសរសេរនឹងព្យញ្ជនៈអឃោសៈវិញ ។ ឧ. ប័រ (ខ្លាញ់ទឹកដោះគោ) ទោះជាក្នុងវចនានុក្រមខ្មែរ លោកថា ត្រូវសរសេរ ប៊័រ ; បៀរម៉ាកអានផ័រ ; សារព័ត៌មានកំបូជស័រ ។ ខ្ញុំបាទគិតថា គួរតែរំឭកកូនខ្មែរឲ្យសរសេរ ប៊័រ អានឈ័រ និងកំបូដស៊័រ វិញ ព្រោះថា ក្នុងគ្រាមភាសាខ្មែរមួយចំនួន ឧទាហរណ៍នៅស្រុករៀងក្នុងខេត្តព្រះវិហារ ឬនៅខេត្តសុរិន្ទ ខ្ញុំបាទបានឮបងប្អូនខ្មែរ មិនច្រឡំ ◌័រ និង ◌៊័រ ឡើយ ។ ឧទាហរណ៍ គេថា «អ័រ-ក» (អារ់ក គឺ អារ-ក) ហើយពាក្យថា អ័រ គេបញ្ចេញសម្លេងខ្លី (អារ់)

ខុសពី «អារ» (ឧ. ប្រពន្ធអារ) មានសូរសម្លេងវែង ។ ពាក្យទាំងនេះ ឮ «រ» ប្រកបយ៉ាងច្បាស់ ។ «ធ្វើការ» គេនិយាយថា «ធ្វើការ» (ឮទាំងស្រៈអាវែង និង រ ប្រកប) ខុសពី “មេឆ្កែក័រ (កាវ់) កូន” (គឺ មេឆ្កែការកូន) ហើយខុសពី «ម៉ែមានគ័ភ៌» (ឮថា គ័រ) គឺថា «ការ» «ក័រ» និង «គ័រ» មានសំឡេងខុសគ្នានៅក្នុងខេត្តទាំងនោះ ។

[8] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្នែល ឫទ្ធី អង់តែល្ម** ៖ យុគលពិន្ទុ មានប្រើក្នុងពាក្យខ្មែរមួយចំនួនតូច ដូចជា រយៈ ហេៈ ឬ ហៃៈ (សូរលាន់មាត់) អុឺថាៈ វូមវៈ ! អ្ហាៈ ! និងពាក្យមួយមកពីចិន ៖ ប៉ិក្វៈ (ជំឡូងល្វីស) (នេះគឺជាអក្ខរាវិរុទ្ធរបស់វចនានុក្រមខ្មែរ តែខ្ញុំបាទឃើញថា គេច្រើនសរសេរ ប៉ិគក់ វិញ ក្នុងសៀវភៅធ្វើម្ហូប) ។ ក្នុងវចនានុក្រមខ្មែរ លោកហៅយុគលពិន្ទុថា ជាវណ្ណយុត្តិ តែក្នុងវិស័យភាសាសាស្ត្រ ខ្ញុំបាទយល់ថា អាចទុកថា នៅក្នុងចំណោមស្រៈ ឬ ស្រៈនិង ក ប្រកប វិញ ។

[9] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្នែល ឫទ្ធី អង់តែល្ម** ៖ គួរសរសេរ កណ្ដុកសញ្ញា វិញ ទោះជាអានថា កណ្ដក់ ក៏ដោយ ព្រោះ កណ្ដុក ជាពាក្យបាលី មានន័យថា បន្លា ។

[10] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្នែល ឫទ្ធី អង់តែល្ម** ៖ រឿងក្បៀសជារឿងសំខាន់បំផុត បើនិយាយពីរឿងតួលេខ ដែលគួរតែយកមកពិភាក្សា ដោយហេតុតែ ពីមុន ខ្មែរយើងបានទទួលឥទ្ធិពលពីបារាំងសែសយ៉ាងខ្លាំងក្លា ។ «ពីរកន្លះ» យើងសរសេរថា ២,៥ តាមទម្លាប់បារាំង (ប្រើក្បៀស) ។ តែសព្វថ្ងៃ ឥទ្ធិពលបរទេសមកពីអាមេរិកាំងវិញ ហើយពួកអាគាំងសរសេរថា ២.៥ (ប្រើចំណុច) ។ សព្វថ្ងៃ ឃើញថា មានពួកក្មេង ៗ និយមសរសេរដូចអាមេរិកាំងដែរ ។ «បីពាន់» អាមេរិកាំង (ឬពួកអង់ក្លូសាក់សុងជាទូទៅ) សរសេរជាលេខថា ៣,០០០ (សៀមក៏សរសេរដូច្នេះដែរ ៖ ๓,๐๐๐) ឯបារាំងវិញ សរសេរថា ៣ ០០០ (ដាក់ចន្លោះភ្ជាប់ក្រោយពីខ្ទង់ពាន់) ឬ ៣០០០ ឬ ៣.០០០ ក៏បាន ។ ខ្មែរធ្លាប់ធ្វើតាមបារាំងយូរមកហើយ ជាងមួយសតវត្ស តែត្រូវសម្រេចចិត្ត យករបៀបណា របស់អាមេរិកាំង ឬ របស់បារាំង ?

[11] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្នែល ឫទ្ធី អង់តែល្ម** ៖ តាមយោបល់ខ្ញុំបាទ ទោះជាមានគេនិយមសរសេរ «កម្មវត្ថុៈ» «យោងៈ» ។ល។ នេះគួរមិនទុកថា ត្រឹមត្រូវទេ ព្រោះធ្វើឲ្យច្រឡំតួនាទីរបស់យុគលពិន្ទុនិងទ្វិពិន្ទុលេខ ។ គួរសរសេរ «កម្មវត្ថុ» ៖ «យោង» ៖ វិញ ព្រោះសព្វថ្ងៃយើងមានយូនីកូដខ្មែរ ។

[12] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្សែល ឫទ្ធី អង់តែល្ម** ៖ តាមយោបល់ខ្ញុំបាទ កូនសិស្សខ្មែរ ដែលរៀនក្បួនខ្នាតអក្ខរាក្រមនិងវេយ្យាករណ៍ខ្មែរ មិនអាចយល់កថាខណ្ឌខាងលើ ព្រោះពួកគេមានភាសាខ្មែរជាភាសាកំណើត ហើយមិនចេះភាសាបារាំង ព្រោះហេតុថា ភាសាបារាំង ពុំសូវមានអ្នកណារៀនសព្វថ្ងៃនេះ ។ មានតែមនុស្សដែលបានទទួលការអប់រំនៅសម័យអាណាព្យាបាល ឬ សង្គមនិយម ដែលអាចយល់បាន ។ ហើយបើសិនជាត្រូវការខណ្ឌសញ្ញា គួរប្រើទ្វិពិន្ទុលេខ (ចំណុចពីរគូស ៖) ជំនួសយុគលពិន្ទុ (ះ) វិញ ។

[13] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្សែល ឫទ្ធី អង់តែល្ម** ៖ ខ្ញុំគិតថា គួរប្រើ (៖) វិញ ព្រោះមានចុចពីរក្នុងពាក្យថា អ៊ីថាៈហើយ អាចនាំឲ្យមានការយល់ច្រឡំ ។ ឧ. "ឯងថា មិនឲ្យគ្នាទៅអ៊ីថាៈ បានជាគ្នាមិនទៅ !" ។

[14] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្សែល ឫទ្ធី អង់តែល្ម** ៖ លោក នួន ប៊ុត ហៅសញ្ញានេះថា វិឡារសញ្ញា, អញ្ញប្រកាស ឬ កោណសញ្ញា ហើយសរសេរថា "» មានឈ្មោះដូចគ្នា ។

[15] ទស្សនៈលោកសាស្ត្រាចារ្យ មីស្សែល ឫទ្ធី អង់តែល្ម ៖ លោក នួន ប៊ុត ហៅសញ្ញានេះថា អន្តរសញ្ញា ។

[16] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្សែល ឫទ្ធី អង់តែល្ម** ៖ ប្រការនេះជាការពិបាកនិងស្មុគស្មាញបន្តិចដូចលោកបានយកមក ពិភាក្សា ព្រោះខ្ញុំឃើញថា អ្នកប្រាជ្ញខ្មែរទាំងឡាយ មិនប្រើឈ្មោះដូចគ្នាទេ ។ ឧទាហរណ៍ លោក **នួន ប៊ុត** ហៅ " " និង "» ថា វិឡារសញ្ញា ហើយថា ហៅថា អញ្ញប្រកាស ក៏បាន ។ រួចលោកថា "នឹងហៅថា កោណសញ្ញា ដើម្បីឲ្យស្រួលចំណាំកុំឲ្យច្រឡំគ្នាបាន" ។ ភាសាបារាំង គេហៅសញ្ញា "» នេះថា វិឡារសញ្ញាបារាំងសែស និង " " ថា វិឡារសញ្ញាអង់គ្លេស អាចប្រើទាំងពីរបាន តែវិឡារសញ្ញាអង់គ្លេសទុកជាសញ្ញារង គឺមានតួនាទីខុសគ្នាបន្តិច ។ ឧ. "អ្នកកាន់បេឡា បាននិយាយមកកាន់ខ្ញុំថា ៖ "សូមមើល 'ប៉ាស់ស្ព័រ' របស់លោកបន្តិច ។" ខ្ញុំក៏ហុចលិខិតឆ្លងដែនរបស់ខ្ញុំឲ្យគាត់" ។ សញ្ញា "» នេះ ពួកអង់គ្លេសនិងអាមេរិកាំងមិនដែលប្រើឡើយ ប្រើតែ " " ប៉ុណ្ណោះ ។ សូមអ្នកប្រាជ្ញខ្មែរនៅពុទ្ធសាសនបណ្ឌិត្យមេត្តាដាក់ឈ្មោះខុសគ្នាឲ្យខណ្ឌសញ្ញាទាំង ៣ យ៉ាងនេះ ពោលគឺ "», " " និង ' ' កុំឲ្យកូនខ្មែរច្រឡំ ។

[17] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្ហែល ឫទ្ធី អង់តែល្ម** ៖ លេខរ៉ូម៉ាំងមានតួច្រើនទៀត ព្រោះមិនអនុវត្តតាមរបាប់ទសភាគ ហើយលេខរ៉ូម៉ាំងពុំមានលេខសូន្យ ។តួលេខដទៃទៀត គឺ ៖ L (៥០) C (១០០) D (៥០០) M (១០០០) ។

[18] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្ហែល ឫទ្ធី អង់តែល្ម** ៖ កាលខ្ញុំបាទបានរៀនអក្សរខ្មែរ ខ្ញុំបាទក៏ឮគ្រូ ៗ របស់ខ្ញុំបាទហៅអក្សរបែបនេះថា អក្សរមូល (ហើយខ្ញុំបាទកត់សម្គាល់ថា សព្វថ្ងៃនេះ ក្មេង ៗ ជាច្រើនមិនស្គាល់ឈ្មោះនេះ ហៅថា អក្សរឆ្លាក់វិញ) ។ តែតាមការស្រាវជ្រាវរបស់ខ្ញុំបាទ ហៅអក្សរបែបនេះថា អក្សរមូល ក៏ជាការច្រឡំដែរ ។ ទោះបីជាតួអក្សរមានរាងមូលមែនក៏ដោយ តាមពិតគឺជាអក្សរខម ។ ក ខ គ ឃ ង នេះ គឺជាអក្សរខម មិនមែនជាអក្សរមូលទេ ។ នៅស្រុកសៀម គេប្រើអក្សរបែបនេះក្នុងសាស្ត្រាស្លឹករឹត និងក្រាំង (សព្វថ្ងៃនេះ មានមនុស្សតិចណាស់ ដែលចេះអាន ព្រោះស្ដេចសៀមនៅចុងសតវត្សទី ១៩ ដើម ស.វ. ទី ២០ ចង់ផ្សព្វផ្សាយតែអក្សរសៀម ដោយយកលេសថា ជាអក្សរពិបាករៀន និងពិបាកប្រើក្នុងការបោះពុម្ពសៀវភៅ តែតាមទស្សនៈខ្ញុំបាទ គឺមកពីទស្សនៈជាតិនិយម ដែលបានលេចឡើងនៅសម័យនោះ) ។ ដូចលោកមានប្រសាសន៍ ក្នុងសម័យបច្ចុប្បន្ន សៀមនៅតែប្រើអក្សរបែបនេះសម្រាប់សរសេរគាថាលើយ័ន្ត្រ ឬ សាក់លើខ្លួនមនុស្ស ព្រោះជាតួអក្សរស័ក្តិសិទ្ធិ ។ រីឯអក្សរសៀមវិញ គ្រាន់តែជាអក្សរសម្រាប់ផែនដី កិច្ចការរាជការនិងរដ្ឋបាលប៉ុណ្ណោះ ទោះបីជាព្រះត្រៃបិដកជាភាសាបាលី គេសរសេរជាអក្សរសៀមវិញ ។ ពីដើម សៀមមិនដែលសរសេរគាថាបាលី ឬ ពុទ្ធវចនាជាភាសាបាលី ជាអក្សរសៀមឡើយ ។ សៀមហៅអក្សរបែបនេះថា អក្សរខម ព្រោះខម គឺជាជនជាតិខ្មែរ ។ សៀមហៅខ្មែរសម័យអង្គរថា ខម ៗ ។

[19] ទស្សនៈលោកសាស្ត្រាចារ្យ **មីស្ហែល ឫទ្ធី អង់តែល្ម** ៖ ក ខ គ ឃ ង នេះ គឺជាអក្សរមូល មិនមែនជាអក្សរខមទេ ។ ខ្ញុំបានមើលគម្ពីរសៀមជាភាសាសៀមនិងបាលី តែសរសេរជាអក្សរខម (អក្សរខ្មែរ) (រហូតដល់ចុង ស.វ. ទី ១៩ សៀមសរសេរសៀវភៅទេសន៍ភាសាសៀមជាអក្សរខម) ។ ក្នុងសាស្ត្រាទាំងនេះ ខ្ញុំបាទមិនដែលឃើញសៀមសរសេរ ក មានរូបសណ្ឋានជា ក ឬ ង ជា ង ឡើយ ។ គេសរសេរដូចតទៅជានិច្ច ៖ ក និង ង ។ ខ្ញុំបាទបានសាកសួរនិស្សិតជាតិជាណឹម៉ាកម្នាក់ សព្វថ្ងៃ កំពុងធ្វើសរណាស្រាវជ្រាវស្ដីពីរឿង ព្រះមាល័យ របស់សៀម ជាភាសាសៀម តែសរសេរជាអក្សរខ្មែរ ។ គាត់បានប្រាប់ខ្ញុំថា គាត់បានអានក្រាំងនិងសាស្ត្រាស្លឹករឹតច្រើនច្បាប់ ច្រើនខ្សែ មកពីប្រទេសសៀម បានប្រទះឃើញតួ ក តែម្ដងគត់ ក្នុងឃ្លាចុងបញ្ចប់រឿងមួយ (សរសេរជាភាសាសៀម) ។ ចំណែកឯរបៀបសរសេរតួ ក ខ គ ឃ ង ខ្ញុំបាទបានប្រទះឃើញជាញឹកញាប់បំផុតក្នុងសាស្ត្រាស្លឹករឹត វាន និងសៀវភៅសរសេរដែលពួក

បារាំងបាននាំមកប្រើនៅប្រទេសកម្ពុជានៅចុង សតវត្សទី ១៩ ។ ដែលអ្នកប្រាជ្ញសព្វថ្ងៃ ច្រឡំអក្សរមូលនិងអក្សរខម ខ្ញុំបាទគិតថា មានមូលហេតុ ២ ។ ទី ១ នៅប្រទេសកម្ពុជា អក្សរខមមានប្រជាប្រិយភាពខ្លាំងនៅ ស.វ. ទី ២០ ហើយគេបានយកអក្សរនេះសម្រាប់យីហោស្លាក ។ល។ ទី ២ ដល់ពេលយកបែបអក្សរនេះ ធ្វើជាសំណអក្សរពុម្ព គេបានធ្វើឲ្យតួអក្សរបែបនេះ មានរាងថ្លោស និងមូលទៀត ។ ឯអក្សរមូលវិញ គេមិនបានធ្វើឲ្យសំណពុម្ពមានរាងថ្លោស ។ ម្យ៉ាងទៀត គេបានធ្វើឲ្យមានរូបជ្រុងបន្តិច ។

ដែល ខ្ញុំបានរៀបរាប់នេះ ប្រហែលជាការយល់ខុសពីខ្ញុំបាទ តែខ្ញុំបាទបានប្រមូលឯកសារជាភស្តុតាង ដែលខ្ញុំបានស្នេន និងសូមជូនក្នុងឯកសារមួយទៀត ។

[20] ទស្សនៈលោកសាស្រ្តាចារ្យ **មីស្ហែល ឫទ្ធី អង់តែល្ម** ៖  ម តួនេះ ពុំមែនជាព្យញ្ជនៈ ម (ម) ទេ គឺជាតួព្យញ្ជនៈ ម (ហៅ សប) ជាព្យញ្ជនៈសម្រាប់តែភាសាសំស្រ្កឹត ពុំមានក្នុងភាសាបាលី និងខ្មែរទេ ។ ភាសាសំស្រ្កឹតមានព្យញ្ជនៈ «ស» បីតួ (បញ្ចេញសម្លេងខុសគ្នា) គឺ គ (ហៅ សក) ម (ហៅ សប) និង ស (អាចហៅ សល) បាន ។ រីឯភាសាបាលី មានតែតួ ស ប៉ុណ្ណោះ ។ ខ្មែរធ្លាប់ប្រើ គ និង ម តាំងពីសម័យមុនអង្គររហូតដល់សម័យក្រោយអង្គរ ។ ឧ. សូមមើល សិលាចារឹកនគរវត្ត និង បទានុក្រម រៀបរៀងដោយ**មហាពិទូរក្រសេម** ភ្នំពេញ ពុទ្ធសាសនបណ្ឌិត្យបោះពុម្ពលើកទី ២ គ.ស. ១៩៥៨ ព.ស. ២៥០១ ។

[21] ទស្សនៈលោកសាស្រ្តាចារ្យ **មីស្ហែល ឫទ្ធី អង់តែល្ម** ៖ នៅក្នុងសៀវភៅបោះពុម្ពផ្សាយនៅស្រុកខ្មែររហូតដល់សម័យសង្គម រាស្រ្តនិយម ស្រៈ ែ នេះ ក៏មានរូបសណ្ឋានដូចនេះ ែ ផងដែរ ។

[22] ទស្សនៈលោកសាស្រ្តាចារ្យ **មីស្ហែល ឫទ្ធី អង់តែល្ម** ៖  នៅភាគកណ្តាលនៃប្រទេសកម្ពុជា គេបញ្ចេញសម្លេងថា ព្រះធរនី តែនៅសុរិន្ទ គេបញ្ចេញសម្លេងថា ព្រះធរណី មិនបញ្ចេញសម្លេងថា ព្រះធរនី (ហើយចំពោះខ្មែរសុរិន្ទ សម្លេងនេះមិនមែនជាឥទ្ធិពលសៀម ព្រោះសៀមមិនអាចបញ្ចេញខ្យល់ ី (អី) ដូចខ្មែរទេ ។

[23] ទស្សនៈលោកសាស្រ្តាចារ្យ **មីស្ហែល ឫទ្ធី អង់តែល្ម** ៖ ក្នុងចម្រៀងមួយចំនួន ខ្ញុំបាទបានឮគេថា ប្រពៃណី តាមអក្ខរាវិរុទ្ធ ទោះជាខ្មែរភាគច្រើនថា ប្រពៃនី ដូចលោកមានប្រសាសន៍ ។